ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សៀវភៅណែនាំ

# ស្តីពី

# នីតិវិធីប្រតិបត្តិកិច្ចការពារជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ

រៀបចំដោយ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ឆ្នាំ២០២៤

**ឧបត្ថម្ភដោយ**

IOM UN MIGRATION | ASIA REGIONAL MIGRATION PROGRAM

# អារម្ភកថា

ប្រទេសកម្ពុជាក៏ដូចជាបណ្ដាប្រទេសមួយចំនួនក្នុងតំបន់ និងសកលបាននិងកំពុងជួបប្រទះនឹងបញ្ហារីករាលដាលនៃអំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ការរំលោភបំពានផ្លូវភេទ និងទម្រង់ផ្សេងៗនៃការរំលោភបំពាន ដែលបានប្រព្រឹត្តដោយក្រុមឧក្រិដ្ឋជន និងមនុស្សមួយចំនួនដោយគ្មានការខ្លាចញញើតក្នុងគ្រប់រូបភាពដែលភាគច្រើនជាឧក្រិដ្ឋកម្មឆ្លងដែន។ ជាការឆ្លើយតប រាជរដ្ឋាភិបាលបានបង្កើតច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ លិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីប្រតិបត្តិ ព្រមទាំងបានបង្កើត«គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស» មាន២២ ក្រសួង ស្ថាប័ន ជាសមាជិក និងមានក្រុមការងារអន្តរក្រសួង ស្ថាប័នចំនួន ៦ ក្នុងនោះក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាដឹកនាំក្រុមការងារការពារជនរងគ្រោះ មានភារកិច្ចផ្ដល់សេវាស្ដារសម្បទា ធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទទៅគ្រួសារ និងសង្គមវិញ។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានភារកិច្ច គ្រប់គ្រង ដឹកនាំ និងចាត់ចែងការងារគាំពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងរំលោភផ្លូវភេទ ឬទម្រង់ផ្សេងទៀតនៃការរំលោភបំពានតាមបែបទាសភាពសម័យទំនើប។ ដើម្បីផ្ដល់កិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ក្រសួងសហការជាមួយអង្គការអន្តរជាតិទេសន្តរប្រវេសន៍(IOM)បានរៀបចំបង្កើតសៀវភៅណែនាំស្ដីពីនីតិវិធីប្រតិបត្តិកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទក្នុងគោលបំណងផ្ដល់ជានីតិវិធីក្នុងការទទួល និងគ្រប់គ្រងករណីជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ ដែលជាផ្នែកមួយនៃប្រព័ន្ធបញ្ជូនករណីជនរងគ្រោះទាំងនៅក្នុងប្រទេស និងក្រៅប្រទេស។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះកិច្ចសហការ និងសហប្រតិបត្តិការ និងភាពជាដៃគូពីសំណាក់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ដែលបានខិតខំផ្ដល់ជាតុចូល និងកែសម្រួលសៀវភៅណែនាំនេះប្រកបដោយជោគជ័យ។ ក្រសួងសង្ឃឹមថាមន្ត្រីទទួលបន្ទុកគាំពារជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទនៅទីស្ដីការក្រសួង មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត មន្ត្រីទទួលបន្ទុក ជាបុគ្គលិកសង្គមកិច្ចក្រុង ស្រុក ខណ្ឌ អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារ ឃុំ សង្កាត់ និងអ្នកពាក់ព័ន្ធ ចូលរួមអនុវត្តសៀវភៅណែនាំនេះប្រកបដោយការទទួលសខុសត្រូវខ្ពស់។ ក្រសួងនឹងរង់ចាំទទួលយកនូវមេរៀន និងបទពិសោធន៍ថ្មីៗដើម្បីធ្វើបច្ចុប្បន្នភាពសៀវភៅណែនាំនេះឱ្យកាន់តែប្រសើរថែមទៀត។

ថ្ងៃពុធ ៧កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែតុលា ឆ្នាំ២០២៤

**រដ្ឋមន្ត្រី**

ជា_សុមេធី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
លេខ ២៣១ ស.អ.យ.

# ប្រកាស
## ស្ដីពី
## ការដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំ
## ស្ដីពីនីតិវិធីប្រតិបត្តិកិច្ចការពារជនរងគ្រោះដោយ
## អំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ

## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែង តាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែល ប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្សទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែល ប្រកាសឱ្យច្បាប់ស្ដីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៩៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ២០២២ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញប្រកាសលេខ ១២៧៤ ស.អ.យ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៤ ស្ដីពីបទដ្ឋានអប្បបរមាសម្រាប់ថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទដែលស្នាក់នៅក្នុងមជ្ឈមណ្ឌល
- បានឃើញប្រកាសលេខ២១៧៨ ស.អ.យ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៥ ស្ដីពីការដាក់ឱ្យអនុវត្តឧបករណ៍ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ និងបទដ្ឋានអប្បបរមាស្ដីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស
- សារាចរណែនាំលេខ ០១១ ស.អ.យ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២២ ស្ដីពីការងារសមាហរណកម្ម និងតាមដានជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងរំលោភបំពានផ្លូវភេទ ដែលបានស្នាក់នៅក្នុងមជ្ឈមណ្ឌលរដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍
- តាមការចាំបាច់របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា



ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ, ទូរស័ព្ទ/ទូរសារ: (៨៥៥) ២៣ ៧២៦ ០៨៦
Ministry of social Affairs, Veterans and Youth Rahabilitation, #788, Monivong Blvd., Phnom Penh, Cambodia, Fax/Phine: (855) 23 726 086

## សម្រេច

**ប្រការ ១.-**

ត្រូវបានដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្តីពីនីតិប្រតិបត្តិកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ដែលបានចុះថ្ងៃពុធ ៧កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២៤។

**ប្រការ ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសាផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៣._**

នាយកខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាននិងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអ្នកពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ៧កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ២០២៤

**រដ្ឋមន្ត្រី**

ជា សុមេធី

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- រាជកិច្ច
- ប្រការ ៣ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

# មាតិកា


**ផ្នែកទី១ ៖ សេចក្តីផ្តើម** ........ ១

**ផ្នែកទី២៖ គោលបំណង និងវិសាលភាព** ........ ៤

**២.១.គោលបំណង** ........ ៤

**២.២.វិសាលភាព** ........ ៤

**ផ្នែកទី៣៖ និយមន័យ និងវាក្យសព្ទ** ........ ៤

**ផ្នែកទី៤៖ គោលការណ៍អនុវត្តចំពោះជនរងគ្រោះ ឬបុគ្គលសង្ស័យថារងគ្រោះ** ........ ៧

**៤.១.លក្ខខណ្ឌទទួលជនរងគ្រោះ** ........ ៧

**៤.២.ការគោរពសិទ្ធិជនរងគ្រោះ** ........ ៧

**៤.៣.គោលការណ៍មិនបង្កគ្រោះថ្នាក់** ........ ៩

៤.៣.១.ក្របខ័ណ្ឌអន្តរជាតិ ........ ៩

៤.៣.២.ក្របខ័ណ្ឌអាស៊ាន ........ ១០

**៤.៤.ក្រមសីលធម៌វិជ្ជាជីវៈកម្លាំងសេវាសង្គម** ........ ១១

៤.៤.១.គុណតម្លៃនិងគោលការណ៍ ........ ១១

៤.៤.២.ក្រមសីលធម៌កម្លាំងសេវាសង្គម ........ ១៥

**ផ្នែកទី៥៖ នីតិវិធីទទួលជន និងគ្រប់គ្រងករណីជនរងគ្រោះ** ........ ១៨

**៥.១.ការទទួលជនរងគ្រោះ ឬបុគ្គលសង្ស័យថារងគ្រោះផ្តល់សេវាសង្គមកិច្ច** ........ ១៨

ជំហានទី១៖ការទទួលជនរងគ្រោះ និងសម្របសម្រួលការកំណត់អត្តសញ្ញាណ ........ ១៩

ជំហានទី២៖ការដោះស្រាយករណីជនរងគ្រោះ ឬបុគ្គលសង្ស័យថារងគ្រោះ ........ ២១

**៥.២.ការគ្រប់គ្រងករណីជនរងគ្រោះ** ........ ២១

ជំហានទី១៖ទទួលជនរងគ្រោះ និងបើកករណី ........ ២៣

ជំហានទី២៖ការប៉ាន់ប្រមាណគ្រប់ជ្រុងជ្រោយ ........ ២៤

ជំហានទី៣៖រៀបចំផែនការសម្រាប់ករណី ........ ២៨

ជំហានទី៤៖ការអនុវត្តផែនការសម្រាប់ករណី ........ ២៩

ជំហានទី៥៖ការតាមដាន និងពិនិត្យឡើងវិញ ........ ៣០

ជំហានទី៦៖ការបិទករណី ........ ៣២

**ផ្នែកទី៦៖ យន្តការគាំទ្រ** ........ ៣៤

**៦.១.នាយកដ្ឋានគាំពារជនរងគ្រោះ** ........ ៣៤

**៦.២.មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត**........................ ៣៤
**៦.៣.ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ**..... ៣៥
**៦.៤.រដ្ឋបាលឃុំ សង្កាត់**........................................................................................ ៣៦
**៦.៥.មជ្ឈមណ្ឌលរដ្ឋ ឬអង្គការមិនមែនរដ្ឋាភិបាល** ............................................................ ៣៦
**ឧបសម្ព័ន្ធ**.................................................................................................................. ៣៧

## ផ្នែកទី១៖ សេចក្តីផ្តើម

ប្រទេសកម្ពុជាក៏ដូចជាបណ្តាប្រទេសមួយចំនួនក្នុងតំបន់ និងសកលលោក បាននិងកំពុងជួបប្រទះបញ្ហារីករាលដាលនៃអំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ការរំលោភបំពានផ្លូវភេទ និងទម្រង់ផ្សេងៗនៃការរំលោភបំពាន ដែលបានប្រព្រឹត្តដោយក្រុមឧក្រិដ្ឋជន។ ជាការឆ្លើយតប រាជរដ្ឋាភិបាលបានបង្កើតច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ២០០៨ គោលនយោបាយ បទដ្ឋានគតិយុត្ត និងបានបង្កើត«គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)» មាន ២២ ក្រសួង ស្ថាប័នជាសមាជិក និងមានអគ្គលេខាធិការដ្ឋានមួយចំណុះក្រសួងមហាផ្ទៃ ជាយន្តការអន្តរស្ថាប័នថ្នាក់ជាតិដែលមានតួនាទីធ្វើជាសេនាធិការជូនរាជរដ្ឋាភិបាលក្នុងការដឹកនាំ និងសម្របសម្រួលប្រមូលផ្តុំការចូលរួមកិច្ចសហការ និងការគាំទ្រពីក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការសហប្រជាជាតិ ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន។ គ.ជ.ប.ជ មាន ៦ ក្រុមការងារអន្តរក្រសួងស្ថាប័នដូចខាងក្រោម៖

- ក្រុមការងារបង្ការទប់ស្កាត់ ដឹកនាំដោយ ក្រសួងអប់រំ យុវជន និងកីឡា
- ក្រុមការងារការពារជនរងគ្រោះ ដឹកនាំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រុមការងារអនុវត្តច្បាប់ ដឹកនាំដោយអគ្គស្នងការដ្ឋាននគរបាលជាតិ
- ក្រុមការងារកិច្ចការយុត្តិធម៌ ដឹកនាំដោយក្រសួងយុត្តិធម៌
- ក្រុមការងារទេសន្តរប្រវេសន៍ ដឹកនាំដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រុមការងារសហប្រតិបត្តិការអន្តរជាតិ ដឹកនាំដោយ ក្រសួងកិច្ចការនារី

គ.ជ.ប.ជ. មានតួនាទី ជំរុញ និងលើកកម្ពស់ការអនុវត្តច្បាប់ស្តីពីការការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ពិធីសារស្តីពីការទប់ស្កាត់ ការបង្ក្រាបនិងដាក់ទណ្ឌកម្ម អំពើជួញដូរមនុស្សជាពិសេសស្ត្រីនិងកុមារ ដែលបំពេញបន្ថែមលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រឆាំងនឹងឧក្រិដ្ឋឆ្លងដែនដែលមានអង្គការចាត់តាំង ឬលិខិតតុបករណ៍និងកិច្ចព្រមព្រៀងអន្តរជាតិផ្សេងៗទៀតទាក់ទងនឹងអំពើជួញដូរមនុស្ស។ តាមដានត្រួតពិនិត្យ និងវាយតម្លៃសភាពការណ៍ប្រែប្រួលនៃបទល្មើសជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងបទល្មើសពាក់ព័ន្ធ ដទៃទៀត ដោយយកចិត្តទុកដាក់លើភាពរងគ្រោះរបស់ប្រជាពលរដ្ឋទាំងស្ត្រី បុរស ជាពិសេសកុមារនិងយុវវ័យ។ ជំរុញឱ្យមានមជ្ឈមណ្ឌលគំរូ ដែលអនុវត្តតាមបទដ្ឋានបានត្រឹមត្រូវ សម្រាប់ការស្តារនីតិសម្បទាជនរងគ្រោះ មាតុភូមិនិវត្តន៍ មុននឹងធ្វើសមាហរណកម្មទៅគ្រួសារ និងសហគមន៍វិញ។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដឹកនាំក្រុមការងារការពារជនរងគ្រោះទទួលបន្ទុកការផ្តល់សេវាស្តារនីតិសម្បទា ធ្វើមាតុភូមិនិវត្ត និងសមាហរណកម្មជនរងគ្រោះ ដោយអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចនិងទម្រង់ផ្សេងៗទៀតនៃការរំលោភបំពាន។ ដើម្បីផ្តល់កិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចផ្លូវភេទ និងទម្រង់ផ្សេងៗទៀតនៃការរំលោភបំពាន ក្រសួងសហការជាមួយអង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) បានរៀបចំបង្កើតសៀវភៅណែនាំស្តីពីនីតិវិធីប្រតិបត្តិកិច្ចការពារជនរងគ្រោះដោយអំពើជួញដុរមនុស្ស និងអាជីវកម្មផ្លូវភេទ ដោយមានការចូលរួមផ្តល់ធាតុចូល និងពិនិត្យកែសម្រួលពីក្រសួង ស្ថាប័ន អង្គការមិនមែនរដ្ឋាភិបាល មន្ត្រីអនុវត្តផ្ទាល់ និងអ្នកពាក់ព័ន្ធនានា។

ការរៀបចំសៀវភៅណែនាំនេះ រៀបចំឡើងដោយផ្អែកលើអនុក្រឹត្យលេខ ៩៤ អនក្រ.បក ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មាត្រា ២១ នាយកដ្ឋានគាំពារជនរងគ្រោះមានភារកិច្ចៈ

- គ្រប់គ្រង ដឹកនាំ និងចាត់ចែងការងារគាំពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងរំលោភផ្លូវភេទ ឬទម្រង់ផ្សេងទៀតនៃការរំលោភបំពានតាមបែបទាសភាពសម័យទំនើប
- អនុវត្តលិខិតបទដ្ឋានគតិយុត្ត សន្ធិសញ្ញា អនុសញ្ញាអន្តរជាតិ និងកិច្ចព្រមព្រៀងអន្តរជាតិនានាដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស រំលោភបំពានផ្លូវភេទ និងទម្រង់ផ្សេងៗទៀត
- អនុវត្តកម្មវិធីមាតុភូមិនិវត្តន៍ជនរងគ្រោះ ជនងាយរងគ្រោះ និងទម្រង់ផ្សេងៗទៀតដោយអំពើជួញដូរមនុស្ស និងរំលោភបំពានផ្លូវភេទ
- អនុវត្តការកំណត់អត្តសញ្ញាណ អន្តរាគមន៍វិបត្ត ការបញ្ជូន ការទទួល ការរៀបចំផែនការករណី ការប៉ាន់ប្រមាណ ការស្តារ ការធ្វើសមាហរណកម្ម ការតាមដាន ការបិទករណី និងការឧបត្ថម្ភគាំទ្រដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស រំលោភបំពានផ្លូវភេទ និងទម្រង់ផ្សេងៗទៀត
- គ្រប់គ្រងទិន្នន័យជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងរំលោភបំពានផ្លូវភេទគ្រប់ទម្រង់នៃការរំលោភបំពាន
- គាំពារជនរងគ្រោះ និងសាក្សីក្នុងរឿងក្តីក្នុងតុលាការ
- រៀបចំមណ្ឌលស្តារនីតិសម្បទាជនរងគ្រោះ និងសម្របសម្រួលមជ្ឈមណ្ឌលសំចតសម្រាប់ផ្តល់សេវាសង្គមកិច្ចដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស រំលោភផ្លូវភេទ និងទម្រង់ផ្សេងៗទៀតដែលបានធ្វើមាតុភូមិនិវត្តន៍។

ទន្ទឹមនេះ ក៏ផ្អែកលើសៀវភៅកម្រងព័ត៌មានសេវាសាធារណៈរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៤ បានកំណត់សេវាសាធារណៈមាន (ក)ការធ្វើមាតុភូមិនិវត្តន៍ ស្តារនីតិសម្បទា និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ច និងទម្រង់ផ្សេងៗទៀតនៃការរំលោភបំពាន (ខ)ការផ្តល់សេវាស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងសមាហរណកម្មជនរងគ្រោះ។

### ក.ការធ្វើមាតុភូមិនិវត្តន៍ ស្តារនីតិសម្បទា និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ច និងទម្រង់ផ្សេងៗទៀតនៃការរំលោភបំពាន។

- ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលបានអនុម័ត និងប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការ ដោយព្រះរាជក្រម លេខ នស/រកម/០២០៨/០០៥ ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០០៨
- ឯកសារណែនាំស្តីពីនីតិវិធីប្រគល់ និងទទួល ជនរងគ្រោះដោយសារការជួញដូរមនុស្ស រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណៈរដ្ឋសង្គមនិយមវៀតណាម ខែធ្នូ ឆ្នាំ២០១០
- នីតិវិធីប្រតិបត្តិបទដ្ឋានស្តីពីការគ្រប់គ្រងករណីនៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម ជនរងគ្រោះដោយអំពើជួញដូរមនុស្ស រវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ ឆ្នាំ២០១៩
- គោលនយោបាយនិងបទដ្ឋានអប្បបរមាស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ឆ្នាំ២០០៩

- បទដ្ឋានអប្បបរមាសម្រាប់ការថែទាំជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលស្នាក់នៅក្នុងមជ្ឈមណ្ឌល ឆ្នាំ២០១៤
- សារាចរណ៍ណែនាំលេខ ០១១ ស.អ.យ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២២ ស្តីពីការងារសមាហរណកម្ម និងតាមដានជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងរំលោភបំពានផ្លូវភេទដែលបានស្នាក់នូវក្នុងមជ្ឈមណ្ឌលរដ្ឋ អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍
- សេចក្តីសម្រេចលេខ១០៧ ស្តីពីគោលការណ៍ការពារសិទ្ធិជនរងគ្រោះដោយសារការជួញដូរនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៧
- គោលការណ៍ណែនាំស្តីពីការអនុវត្តច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទឆ្នាំ២០០៨
- សេចក្តីណែនាំស្តីពីការអនុវត្តកិច្ចប្រតិបត្តិការសង្គ្រោះជនរងគ្រោះដោយអំពើជួញដូរមនុស្ស និង/ឬការធ្វើអាជីវកម្មផ្លូវភេទ នៅតាមបណ្តាទីតាំងដែលបានកំណត់ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ ២០១០
- គោលការណ៍ណែនាំស្តីពីបែបបទនិងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្សដើម្បីផ្តល់សេវាសមស្រប។

**ខ.ការផ្តល់សេវាស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ**

- អនុក្រឹត្យលេខ ៩០ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួល មាត្រា ៧ នៃអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ ស្តីពី របបគោលនយោបាយចំពោះជនរងគ្រោះថ្នាក់នៅក្នុងមណ្ឌលរដ្ឋ
- អនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ
- ប្រកាសលេខ ២១៧៨ ស.អ.យ. ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៥ ស្តីពីការដាក់ឱ្យអនុវត្តឧបករណ៍ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ និងបទដ្ឋានអប្បបរមាស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស
- ប្រកាសលេខ ១២៧៤ ស.អ.យ. ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៤ ស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើសមាហរណកម្មផ្លូវភេទដែលស្នាក់នៅក្នុងមជ្ឈមណ្ឌល
- នីតិវិធីប្រតិបត្តិបទដ្ឋានស្តីពីការផ្តល់ការគាំទ្រផ្នែកសមាហរណកម្មដល់ជនរងគ្រោះ ជាបុរសដោយអំពើជួញដូរមនុស្ស ខែឧសភា ឆ្នាំ២០១២
- ឯកសារណែនាំស្តីពីនីតិវិធីប្រគល់ និងទទួលជនរងគ្រោះដោយសារការជួញដូរមនុស្ស រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណៈរដ្ឋសង្គមនិយមវៀតណាម ខែធ្នូ ឆ្នាំ២០១០
- សារាចរណែនាំលេខ ០១១ ស.អ.យ. ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២២ ស្តីពីការងារសមាហរណកម្ម និងតាមដានជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងរំលោភបំពានផ្លូវភេទដែលបានស្នាក់នូវក្នុងមជ្ឈមណ្ឌលរដ្ឋ អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍
- ប្រកាសលេខ៨៥២ ស.អ.យ. ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩ លើគោលនយោបាយនិងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស

- សៀវភៅបទដ្ឋានអប្បបរមាសម្រាប់ការថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទដែលស្នាក់នៅក្នុងមជ្ឈមណ្ឌល ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៤ ដោយរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ប្រកាស លេខ ២៩០ ស.អ.យ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះឱ្យនាយកដ្ឋាន និងអង្គភាពក្រោមឱវាទ នៃអគ្គនាយកដ្ឋានសេវាសង្គមកិច្ច
- ប្រកាសលេខ១២៨ ស.អ.យ. ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៧ស្តីពីការបង្កើតមជ្ឈមណ្ឌលសំចតប៉ោយប៉ែត

ការរៀបចំសៀវភៅណែនាំនេះក៏យោងប្រកាសលេខ ១៣៣ ប្រ.ក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីបែបបទនិងនីតិវិធីនៃការកំណត់អត្តសញ្ញាណបឋមជនរងគ្រោះដោយអំពើជួញដូរមនុស្សដើម្បីផ្តល់សេវាសមស្រប និងសារាចរណែនាំលេខ ០១១ ស.អ.យ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២២ ស្តីពីការងារសមាហរណកម្ម និងតាមដានជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងរំលោភបំពានផ្លូវភេទដែលបានស្នាក់នៅក្នុងមជ្ឈមណ្ឌលរដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍។

## ផ្នែកទី២៖ គោលបំណង និងវិសាលភាព

### ២.១.គោលបំណង

គោលបំណងនៃសៀវភៅណែនាំស្តីពីនីតិវិធីប្រតិបត្តិកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទដើម្បី៖

១. ផ្តល់សេវាសង្គមកិច្ចដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ

២. ណែនាំនីតិវិធីទទួលនិងគ្រប់គ្រងករណីជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ

### ២.២.វិសាលភាព

សៀវភៅណែនាំស្តីពីនីតិវិធីប្រតិបត្តិកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទសម្រាប់មន្ត្រីសង្គមកិច្ច[1] មានវិសាលភាពអនុវត្តចំពោះជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទដែលស្ម័គ្រចិត្តទទួលយកសេវាសង្គមកិច្ច ការធ្វើសមាហរណកម្ម និងមាតុភូមិនិវត្តន៍។

## ផ្នែកទី៣៖ និយមន័យ និងវាក្យសព្ទ

**ការជួញដូរមនុស្ស** មានន័យថាជាការជ្រើសរើសការដឹកជញ្ជូន ការផ្ទេរ ការផ្តល់កន្លែងស្នាក់នៅ ឬ ការទទួលមនុស្សដោយប្រើប្រាស់មធ្យោបាយគំរាមកំហែង ឬប្រើប្រាស់កម្លាំង ឬការបង្ខិតបង្ខំក្នុងទម្រង់ផ្សេងទៀត ការចាប់ពង្រត់ ការបន្លំ ការបោកបញ្ឆោត ការរំលោភអំណាច ឬស្ថានភាពងាយរងគ្រោះ ឬការផ្តល់ ឬការទទួលយកការបង់ប្រាក់ ឬអត្ថប្រយោជន៍នានា ដើម្បីទទួលបានការយល់ព្រមពីបុគ្គលម្នាក់ដែលមានសិទ្ធិគ្រប់គ្រងលើបុគ្គលម្នាក់ផ្សេងទៀត ក្នុងគោលបំណងប្រព្រឹត្តអំពើកេងប្រវ័ញ្ច។ អំពើកេងប្រវ័ញ្ច យ៉ាងហោចណាស់ត្រូវរួមមាន ជាអាទិ៍ ការធ្វើអាជីវកម្មពេស្យាចារលើអ្នកដទៃ ឬការធ្វើអាជីវកម្មផ្លូវភេទក្នុងទម្រង់ផ្សេងទៀត ការបង្ខំឱ្យធ្វើពលកម្ម ឬផ្តល់សេវា ទាសភាព ឬការអនុវត្តដែលស្រដៀងគ្នា នឹងទាសភាព ការចាប់បង្ខំឱ្យផ្តល់សេវា ឬការដកហូតយកសរីរាង្គជាដើម។

---

[1] មន្ត្រីទទួលបន្ទុក ថ្នាក់ជាតិ មន្ត្រីទទួលបន្ទុក មន្ទីរ ស.អ.យ "អ្នកត្រួតពិនិត្យករណី" មន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ "អ្នកកាន់ករណី" មន្ត្រី-បុគ្គលិកមជ្ឈមណ្ឌល និងអ្នកពាក់ព័ន្ធការងារសង្គមកិច្ច។

**ការកេងប្រវ័ញ្ចន៍** សំដៅដល់ការកេងប្រវ័ញ្ចសេដ្ឋកិច្ច ឬការកេងប្រវ័ញ្ចផ្លូវភេទ និងរួមបញ្ចូលទាំងពលកម្មកុមារខុសច្បាប់ អំពើជួញដូរសម្រាប់គោលបំណងផ្លូវភេទ ឬពលកម្ម ពលកម្មដោយបង្ខំ និងទម្រង់នៃពលកម្មកុមារដែលត្រូវបានហាមឃាត់ដោយច្បាប់។

*យោងច្បាប់ការងារ មាត្រា១៧៧ ក្មេងដែលមានអាយុពី ១២ ដល់១៥ឆ្នាំ អាចអនុញ្ញាតឱ្យធ្វើការងារស្រាលៗ មិនបណ្តាលឱ្យខូចសុខភាព ឬការអភិវឌ្ឍន៍នៃចិត្ត និងកាយរបស់កុមារ មិនប៉ះពាល់ដល់ការសិក្សាជាទៀងទាត់ ការចូលរួមក្នុងកម្មវិធីតម្រង់ទិស ឬកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈដែលបានកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច។*

**ជនរងគ្រោះដោយអំពើជួញដូរមនុស្ស** គឺជាជនដែលទទួលរងគ្រោះដោយអំពើដែលមានចែងក្នុងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ និងបញ្ញត្តិពាក់ព័ន្ធក្នុងក្របព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដែលបានអនុលោមតាមនិយមន័យនៃ "ការជួញដូរមនុស្ស" ក្នុង**មាត្រា ៣ នៃ<u>ពិធីសារប៉ាឡឺម៉ូ</u>**។

<u>**ពិធីសារប៉ាឡឺម៉ូ** បានឱ្យនិយមន័យ "បទល្មើសជួញដូរមនុស្ស" នៅក្នុងមាត្រា៣ ថា៖</u>

(ក)ការជួញដូរមនុស្ស មានន័យថាការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការផ្តល់កន្លងលាក់ខ្លួន ឬការទទួលយកមនុស្ស ដោយមធ្យោបាយគំរាមកំហែង ឬការប្រើកម្លាំង ឬ ការបង្ខិតបង្ខំតាមរូបភាពផ្សេងៗ ដូចជាការចាប់ពង្រត់ ការក្លែងបន្លំ ការបោកបញ្ឆោត ការរំលោភលើអំណាច ឬតួនាទីទៅលើជនដែលងាយទទួលរងគ្រោះ ឬការផ្តល់ ឬការទទួលជាលុយកាក់ ឬផលកម្រៃផ្សេងៗដើម្បីឱ្យមានការយល់ព្រមពីអ្នកគ្រប់គ្រងលើជនម្នាក់ទៀតក្នុងគោលបំណងដើម្បីធ្វើការកេងប្រវ័ញ្ច។ ការកេងប្រវ័ញ្ចត្រូវរាប់បញ្ចូលជាអប្បបរមា ការធ្វើអាជីវកម្មពេស្យាចារលើអ្នកដទៃ ឬការកេងប្រវ័ញ្ចផ្លូវភេទ តាមរូបភាពផ្សេងទៀត ការងារដោយបង្ខំ ឬសេវាកម្មទាសភាព ឬការអនុវត្តដែលមានលក្ខណៈស្រដៀងគ្នា ទៅនឹងទាសភាព ភាពជាអ្នកបម្រើជាប់ថ្លៃ ឬការដកហូតសរីរាង្គជាដើម។

(ខ)ការយល់ព្រមរបស់ជនរងគ្រោះដោយអំពើជួញមនុស្ស ចំពោះការកេងប្រវ័ញ្ចដែលបានធ្វើឡើងដោយចេតនាដូចមានចែងក្នុងវាក្យខ័ណ្ឌ(ក)នៃមាត្រានេះនឹងមិនអាចយកជាការបានឡើយ ប្រសិនបើមធ្យោបាយណាមួយដែលមានចែងក្នុងវាក្យខ័ណ្ឌ(ក) ត្រូវបានយកមកប្រើប្រាស់។

(គ)ការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការផ្តល់កន្លែងលាក់ខ្លួនឬការទទួលយកកុមារក្នុងគោល បំណងធ្វើ អាជីវកម្មត្រូវចាត់ទុកថាជា ការជួញដូរមនុស្ស ទោះបីជាអំពើនេះ មិនជាប់ពាក់ព័ន្ធទៅនឹងមធ្យោបាយណាមួយមានចែងក្នុងវាក្យខ័ណ្ឌ(ក)នៃមាត្រានេះក៏ដោយ។

**កម្លាំងសេវាសង្គម៖** គឺសំដៅដល់ជនទាំងឡាយណា ទាំងមន្ត្រីរាជការ បុគ្គលិកសមាគម និងអង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន និងរូបវន្តបុគ្គល ទោះជាអ្នកអាជីព អ្នកអាជីពរង ឬអ្នកមានជំនាញច្បាស់លាស់ផ្នែកការងារសង្គមកិច្ច ដោយយកកម្រៃ ឬមិនយកកម្រៃ ធ្វើការដើម្បីធានាបាននូវការអភិវឌ្ឍសុខុមាលភាពរបស់អតិថិជន។ កម្លាំងសេវាសង្គមត្រូវមានគុណតម្លៃស្នូលរបស់ខ្លួនបីយ៉ាងរួមមានការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស យុត្តិធម៌សង្គម និងសុចរិតភាពវិជ្ជាជីវៈ។ កម្លាំងសេវាសង្គមមានប្រភេទដូចជា៖ **អ្នកអាជីពសង្គមកិច្ច អ្នកអាជីពសង្គមកិច្ចរង អ្នកសង្គមកិច្ចបឋម និងអ្នកសង្គមកិច្ចសម្ព័ន្ធ។**

**សំគាល់៖ កម្លាំងសេវាសង្គម** រួមបញ្ចូលមន្ត្រីទទួលបន្ទុក មន្ទីរ ស.អ.យ មន្ត្រីទទួលបន្ទុក ថ្នាក់ជាតិ មន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ និងមន្ត្រី-បុគ្គលិកមជ្ឈមណ្ឌល ។

**មន្ត្រីទទួលបន្ទុក មន្ទីរ ស.អ.យ** សំដៅដល់មន្ត្រីទទួលបន្ទុកគាំពារជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត។

**មន្ត្រីទទួលបន្ទុក ថ្នាក់ជាតិ** សំដៅដល់មន្ត្រីទទួលបន្ទុកគាំពារជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ នាយកដ្ឋានគាំពារជនរងគ្រោះ នៃអគ្គនាយកដ្ឋានសេវាសង្គមកិច្ច ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**មន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ**[2] សំដៅដល់មន្ត្រីទទួលបន្ទុកការងារសង្គមកិច្ចការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

**មន្ត្រី-បុគ្គលិកមជ្ឈមណ្ឌល** សំដៅដល់មន្ត្រី-បុគ្គលិកមជ្ឈមណ្ឌលរដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាលដែលផ្តល់សេវាដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ ហើយមានកិច្ចព្រមព្រៀងជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**ការធ្វើមាតុភូមិនិវត្តន៍ ស្តារនីតិសម្បទា និងសមាហរណកម្ម ជនរងគ្រោះដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ច និងទម្រង់ផ្សេងៗទៀតនៃការរំលោភបំពាន៖**

- ការធ្វើមាតុភូមិនិវត្តន៍(ការទទួល និងបញ្ជូន)ដោយអំពើជួញដូរមនុស្សអំពើធ្វើអាជីវកម្ម ផ្លូវភេទ ការកេងប្រវ័ញ្ច និងទម្រង់ផ្សេងៗទៀតនៃការរំលោភបំពាន៖
    - ប្រសិទ្ធភាពក្នុងការទទួលជនរងគ្រោះ ក្រោយពីអន្តរាគមន៍វិបត្តិ
    - ប្រសិទ្ធភាពក្នុងការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះ ទៅប្រទេសដើមវិញ
- ស្តារនីតិសម្បទាដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ច និងទម្រង់ផ្សេងៗទៀតនៃការរំលោភបំពាន៖
    - ប្រសិទ្ធភាពក្នុងការផ្តល់សេវាផ្នែកវេជ្ជសាស្ត្រ
    - ប្រសិទ្ធភាពក្នុងការប្រឹក្សាយោបល់ និងព្យាបាលផ្លូវចិត្តដល់ជនរងគ្រោះ
    - ប្រសិទ្ធភាពក្នុងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ
    - ប្រសិទ្ធភាពក្នុងការផ្តល់សេវាផ្នែកច្បាប់
    - ប្រសិទ្ធភាពក្នុងការពង្រឹងសេដ្ឋកិច្ច
- សមាហរណកម្ម ជនរងគ្រោះដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ច និងទម្រង់ផ្សេងៗទៀតនៃការរំលោភបំពាន ទៅគ្រួសារ និងសហគមន៍
    - ប្រសិទ្ធភាពក្នុងការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះ
    - ប្រសិទ្ធភាពក្នុងការជួយដល់ជនរងគ្រោះមិនឱ្យធ្លាក់ខ្លួនសារជាថ្មី
    - ប្រសិទ្ធភាពក្នុងការផ្តល់នូវសេចក្តីសង្ឃឹម និងបំណិនជីវិតដល់ជនរងគ្រោះ
    - ប្រសិទ្ធភាពក្នុងការជួយដល់ជនរងគ្រោះ ឱ្យក្លាយជាសមាជិកថ្មី រស់នៅក្នុងសហគមន៍
    - ប្រសិទ្ធភាពក្នុងការជួយបង្កើនភាពនឹងនរផ្លូវកាយ ផ្លូវចិត្ត ផ្លូវអារម្មណ៍

---

[2] សេចក្តីណែនាំលេខ ០០៩ ស.អ.យ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីតួនាទីនិងភារកិច្ចសម្រាប់មន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ចក្រុង ស្រុក ខណ្ឌ។

- ប្រសិទ្ធភាពក្នុងការជួយដល់ជនរងគ្រោះ ដើម្បីទំនាក់ទំនងជាមួយគ្រួសារ និងសហគមន៍សារជាថ្មី

**ការផ្តល់សេវាស្តារនីតិសម្បទា និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស៖** ជនរងគ្រោះដោយអំពើជួញដូរមនុស្សបានទទួលការថែទាំ ស្នាក់នៅ របបម្ហូបអាហារ ទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ និងធ្វើសមាហរណកម្មទៅសហគមន៍ដូចខាងក្រោម ៖

- របបម្ហូបអាហារ ស្នាក់នៅក្នុងមជ្ឈមណ្ឌលរយៈពេល ០៣ខែ
- របបសម្លៀកបំពាក់ សម្ភារសិក្សា កីឡា សម្ភារដំណេក ផ្ទះបាយ អនាម័យ និងព្យាបាល
- វគ្គបណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈ សម្រាប់រយៈពេលខ្លី ០៣ខែ
- របបសមាហរណកម្មវិលទៅសហគមន៍វិញ ដើម្បីធ្វើទុនប្រកបមុខរបរ និងកសាងជីវភាពគ្រួសារ។

## ផ្នែកទី៤៖ គោលការណ៍អនុវត្តចំពោះជនរងគ្រោះ ឬបុគ្គលសង្ស័យថារងគ្រោះ

ការឈានទៅដល់ការទទួលជនរងគ្រោះ បុគ្គលសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ ការគ្រប់គ្រងករណី និងសមាហរណកម្មជនរងគ្រោះ នៅក្រោមនីតិវិធីប្រតិបត្តិកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី-ខេត្ត នាយកដ្ឋានគាំពារជនរងគ្រោះ អង្គការមិនមែនរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានា ត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម៖

### ៤.១.លក្ខខណ្ឌទទួលជនរងគ្រោះ

ជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ "ក្នុងស្រុក" ដែលទទួលយកពីមន្ត្រីនគរបាលយុត្តិធម៌ជំនាញ និងជនរងគ្រោះ ឬបុគ្គលសង្ស័យរងគ្រោះដោយអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទពី "ក្រៅស្រុក" តាមច្រកអន្តរជាតិនានា(ផ្លូវអាកាស ផ្លូវគោក និងផ្លូវទឹក)ដែលបញ្ជូនមកពីស្ថានតំណាងកម្ពុជានៅក្រៅប្រទេស និងតាមរយៈក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ទទួលបានកន្លែងនៅបណ្តោះអាសន្ន របបម្ហូបអាហារ សេវាថែទាំ សេវាផ្នែកវេជ្ជសាស្ត្រ សេវាប្រឹក្សាយោបល់និងព្យាបាលផ្លូវចិត្ត សេវាផ្នែកច្បាប់ ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ សមាហរណកម្ម និងមាតុភូមិនិវត្តន៍។ ជនរងគ្រោះរងគ្រោះដោយអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទទទួលបានការគ្រប់គ្រងករណីបន្តដោយមន្ត្រីជំនាញពាក់ព័ន្ធ។

### ៤.២.ការគោរពសិទ្ធិជនរងគ្រោះ

មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ បានចែងថា "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធនារី សិទ្ធិកុមារ។ ប្រជាពលរដ្ឋខ្មែរ មានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើត ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។ ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗមិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ។ ការប្រើប្រាស់សិទ្ធិសេរីភាពនេះត្រូវប្រព្រឹត្តតាមលក្ខខណ្ឌកំណត់ក្នុងច្បាប់"។

សិទ្ធិរបស់ជនរងគ្រោះដោយការជួញដូរ និងអាជីវកម្មផ្លូវភេទ ត្រូវតែជាអាទិភាពខ្ពស់បំផុតនៃគ្រប់កិច្ចខិតខំប្រឹងប្រែងទាំងអស់ដើម្បីទប់ស្កាត់និងប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងដើម្បីផ្តល់កិច្ចការពារ ជំនួយគាំទ្រ និងដំណោះស្រាយជូនជនរងគ្រោះ។ គោលការណ៍ទាំងនេះគប្បីត្រូវបានពិចារណានិងប្រើប្រាស់ជាឯកសារយោងនៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការផ្តល់ការគាំទ្រជូនជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ។

**ការមិនបង្កគ្រោះថ្នាក់៖** មុនពេលធ្វើសកម្មភាពអ្វីមួយគប្បីធ្វើការពិចារណាដើម្បីកាត់បន្ថយជាអតិបរមានូវគ្រោះថ្នាក់គ្រប់ប្រភេទទាំងអស់ដែលនឹងកើតឡើងលើជនរងគ្រោះ(មើលចំណុច ៤.៣)។

**ការគោរព និងសេចក្តីថ្លៃថ្នូរ៖** សិទ្ធិរបស់ជនរងគ្រោះ គប្បីត្រូវបានគោរពក្នុងដំណើរការទាំងមូលនៃការផ្តល់ជំនួយគាំទ្រជូនជនរងគ្រោះ ដោយមិនគិតពីភេទ អាយុ ពូជសាសន៍ ជាតិពន្ធុ សាសនា សញ្ជាតិ និន្នាការភេទ ពិការភាព ឬបទពិសោធន៍កន្លងមកឡើយ។

**ការរក្សាការសម្ងាត់៖** អ្នកផ្តល់សេវាគប្បីរក្សាការសម្ងាត់ការងារនិងព័ត៌មានរបស់ជនរងគ្រោះ លើកលែងតែក្នុងករណីដែលដំណើរការផ្តល់ជំនួយគាំទ្រជូនជនរងគ្រោះតម្រូវឱ្យមានការលាតត្រដាងព័ត៌មាននេះ ឬនៅក្នុងករណីដែលជនរងគ្រោះអនុញ្ញាតឱ្យមានការលាតតដាងព័ត៌មាននេះ។ ក្នុងការលាតត្រដាងព័ត៌មានបែបនេះ អ្នកផ្តល់សេវាគប្បីយល់អំពីភាពខុសគ្នារវាងព័ត៌មានសម្ងាត់ និងព័ត៌មានទូទៅនិងត្រូវរក្សាការសម្ងាត់របស់ជនរងគ្រោះ ជាពិសេសទាក់ទងនឹងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន។

**ការទទួលបានការយល់ព្រម៖** ជនរងគ្រោះម្នាក់ៗគប្បីអាចធ្វើការជ្រើសរើសបានដោយផ្អែកតាមអង្គហេតុពិតទាំងអស់ដោយសេរី និងស្ម័គចិត្ត។

**សិទ្ធិទទួលបានយុត្តិធម៌៖** គោលការណ៍ណែនាំស្តីពីការយកចិត្តទុកដាក់ចំពោះជនរងគ្រោះដោយអំពើជួញដូរមនុស្សជាស្ត្រី។ ជនរងគ្រោះម្នាក់ៗ គប្បីមានសិទ្ធិទទួលបានការព្យាបាលសមស្រប និងលទ្ធភាពទទួលបានយុត្តិធម៌ ដោយផ្អែកតាមច្បាប់ជាតិជាធរមាន។

**អភិក្រមផ្អែកលើសិទ្ធិ/តម្រូវការ៖**អនុលោមតាមអភិក្រមផ្អែកតាមសិទ្ធិ/តម្រូវការជនរងគ្រោះគប្បីចូលរួមប្រកបដោយអត្ថន័យ មានសិទ្ធិទទួលបានព័ត៌មាន និងមិនត្រូវបានរើសអើងនៅក្នុងគ្រប់សកម្មភាពទាំងអស់នៃការរៀបចំផែនការ និងការអនុវត្តដែលពាក់ព័ន្ធនឹងជំនួយត្រូវទទួលបាន។ គប្បីផ្តល់ភាពអង់អាចដល់ជនរងគ្រោះ ដើម្បីឱ្យពួកគេអាចចូលរួមគ្រប់សកម្មភាពទាំងអស់នៃការរៀបចំផែនការ និងការអនុវត្តពាក់ព័ន្ធនឹងជំនួយដែលត្រូវទទួលបានក្នុងករណីសមស្រប។

**ការយល់ដឹងអំពីយេនឌ័រ៖** ភាគីពាក់ព័ន្ធទាំងអស់គប្បីយល់ដឹង និងគោរពសិទ្ធិតម្រូវការ និងការព្រួយបារម្ភ ពិសេសស្ត្រីនិងក្មេងស្រីដើម្បីផ្តល់សេវាសមស្របជូនពួកគេ។ ភាគីពាក់ព័ន្ធទាំងអស់ក៏គប្បីកំណត់ផងដែរនូវយេនឌ័ររបស់ជនរងគ្រោះ ដើម្បីផ្តល់ការគាំទ្រ និងសេវាសមស្របដូចជា សេវាថែទាំសុខភាពសម្ភាសន៍ និងការផ្តល់ជម្រកសុវត្ថិភាព។ល។

## ៤.៣.គោលការណ៍មិនបង្កគ្រោះថ្នាក់

### ៤.៣.១.ក្របខ័ណ្ឌអន្តរជាតិ

ពិធីសារសហប្រជាជាតិស្តីពីការទប់ស្កាត់ បង្ក្រាបនិងផ្តន្ទាទោសអំពើជួញដូរមនុស្ស(២000) ដែលហៅម្យ៉ាងទៀតថា ពិធីសារប៉ាលើម៉ូ (Palermo) អំពាវនាវឱ្យរដ្ឋនានា ផ្តល់ការការពារ និងជំនួយដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ដោយត្រូវមានការគោរពសិទ្ធិមនុស្សរបស់ពួកគេឱ្យបានពេញលេញ។ មាត្រា ៦ ចែងពីការការពារឯកជនភាព និងអត្តសញ្ញាណរបស់ជនរងគ្រោះ ផ្តល់ឱ្យជនរងគ្រោះនូវព័ត៌មានអំពីនីតិវិធីតុលាការធានាថាជនរងគ្រោះបានសះជារាងកាយ ផ្លូវចិត្ត និងសង្គម ផ្តល់សុវត្ថិភាពរាងកាយដល់ជនរងគ្រោះ អនុញ្ញាតឱ្យជនរងគ្រោះស្វែងរកសំណងចំពោះការខូចខាតនានា។

គោលការណ៍ និងគោលការណ៍ណែនាំស្តីពីសិទ្ធិមនុស្ស និងការជួញដូរមនុស្ស ដែលផ្តល់ជាអនុសាសន៍ដោយការិយាល័យនៃឧត្តមស្នងការសិទ្ធិមនុស្ស(OHCHR)អំពាវនាវឱ្យរដ្ឋធានាថាវិធានការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សពុំមានផលប៉ះពាល់អវិជ្ជមានលើសិទ្ធិមនុស្ស និងសេចក្តីថ្លៃថ្នូររបស់មនុស្សឡើយរាប់បញ្ចូលទាំងបុគ្គលដែលត្រូវបានគេជួញដូរផងដែរ(គោលការណ៍ណែនាំទី១)ធានាឱ្យមានការកំណត់អត្តសញ្ញាណជនដែលត្រូវបានជួញដូរឱ្យបានរហ័ស និងដោយសុក្រិត(គោលការណ៍ណែនាំទី២)បង្កើនការយល់ដឹងដល់មន្ត្រីអនុវត្តច្បាប់អំពីសិទ្ធិនិងតម្រូវការរបស់ជនដែលត្រូវបានជួញដូរ (គោលការណ៍ណែនាំទី៥) ផ្តល់ការការពារ និងការគាំទ្រដល់ជនដែលត្រូវបានគេជួញដូរទាំងអស់ដោយពុំមានការរើសអើង (គោលការណ៍ណែនាំទី៦) ដាក់ចេញនូវវិធានការពិសេសដើម្បីផ្តល់ការការពារដល់កុមារដែលត្រូវបានជួញដូរ(គោលការណ៍ណែនាំទី៨)។

គោលការណ៍ណែនាំរបស់យូនីសេហ្វ(UNICEF)ស្តី ពីការការពារកុមារ ដែលជាជនរងគ្រោះនៃអំពើជួញដូរមនុស្ស(២០០៦)កំណត់ពីការត្រៀមរៀបចំទុកជាមុន ការបង្រួបបង្រួមគ្រួសាររបស់កុមារ ដើម្បីកាត់បន្ថយឱ្យនៅតិចបំផុតនូវបញ្ហាផ្លូវចិត្តដែលអាចកើតមានជាថ្មីចំពោះកុមារ និងត្រូវធ្វើការពិចារណាពីហានិភ័យដែលការមាក់ងាយនិងការរងគ្រោះជាថ្មីអាចកើតមានឡើង(កថាខណ្ឌ៩.២)ប្រទេសនានាត្រូវធានាថា សាក្សីដែលជាជនរងគ្រោះអាចផ្តល់ភស្តុតាងប្រកបដោយសុវត្ថិភាព និងត្រូវខិតខំកាត់បន្ថយការប៉ះទង្គិចផ្លូវចិត្តដែលជនរងគ្រោះជារឿយៗតែងតែជួបប្រទះជាបន្តបន្ទាប់នៅក្នុងបន្ទប់តុលាការ (កថាខណ្ឌ១០.១) និងការពារអ្នកចូលរួមក្នុងការស្រាវជ្រាវពីគ្រោះថ្នាក់ផ្លូវចិត្ត ឬរាងកាយដែលអាចកើតឡើងចេញពីការស្រាវជ្រាវការជួញដូរកុមារ (កថាខណ្ឌ ១២.១)។

យោបល់ទូទៅរបស់គណៈកម្មាធិការអនុសញ្ញាសិទ្ធិកុមារ (CRC) លេខ ១៣ (២០១១)ស្តីពីសិទ្ធិរបស់កុមារដើម្បីទទួលបានសេរីភាពរួចផុតពីរាល់ទម្រង់ទាំងអស់នៃអំពើហិង្សា ចែងថា ត្រូវមានការគោរពសិទ្ធិរបស់កុមារ ដើម្បីឱ្យគេអាចស្តាប់ឮសំឡេងរបស់ពួកគេ និងយកគំនិតយោបល់របស់ពួកគេទៅថ្លឹងថ្លែងក្នុងលក្ខណៈជាប្រព័ន្ធក្នុងគ្រប់ដំណើរការធ្វើសេចក្តីសម្រេចចិត្តទាំងអស់ ហើយការលើកស្ទួយភាពអង់អាច និងការចូលរួមរបស់ពួកគេ គួរជាកត្តាសំខាន់នៅក្នុងយុទ្ធសាស្ត្រ និងកម្មវិធីដែលផ្តោតលើការផ្តល់ការថែទាំ និងការពារកុមារ (ផ្នែក ១.៣(e))។

អនុសាសន៍ទូទៅរបស់គណៈកម្មាធិការ CEDAW លេខ ៣៨ (២០២០)ស្តីពីការជួញដូរស្ត្រី និងកុមារក្នុងបរិបទនៃទេសន្តរប្រវេសន៍សកល អំពាវនាវឱ្យរដ្ឋធ្វើការកំណត់អត្តសញ្ញាណ ជួយនិងការការពារជនរងគ្រោះ

នៃអំពើជួញដូរមនុស្សក្របខ័ណ្ឌអន្តរជាតិ ដើម្បីជំរុញការអនុវត្តគោលការណ៍មិនបង្កគ្រោះថ្នាក់ដើម្បីទប់ស្កាត់ការរងគ្រោះជាថ្មីរបស់ពួកគេ និងធានាឱ្យពួកគេអាចទទួលបានយុត្តិធម៌ និងមានការផ្តន្ទាទោសលើជនដែលប្រព្រឹត្តល្មើស(កថាខណ្ឌ ៦)។

អនុសញ្ញាសហប្រជាជាតិស្តីពីសិទ្ធិជនពិការ អំពាវនាវឱ្យរដ្ឋជាសមាជិកធ្វើការប្រយុទ្ធប្រឆាំង និងការប្រកាន់ផ្នត់គំនិតបុរេវិនិច្ឆ័យ និងការអនុវត្តប្រកបដោយគ្រោះថ្នាក់ពាក់ព័ន្ធនឹងជនមានពិការភាពក៏ដូចជាការអនុវត្តទាំងឡាយដែលធ្វើឡើងទៅតាមភេទ និងអាយុ ក្នុងគ្រប់ទិដ្ឋភាពទាំងអស់នៃជីវិត(មាត្រា ៨)។

សេចក្តីប្រកាស របស់អង្គការសហប្រជាជាតិស្តីពីគោលការណ៍ជាមូលដ្ឋានស្តីពីយុត្តិធម៌ សម្រាប់ជនរងគ្រោះ បទល្មើសនិងការរំលោភបំពានអំណាច ផ្តល់ជាអនុសាសន៍ឱ្យជនរងគ្រោះនៃបទល្មើសមានសិទ្ធិទទួលបានការប្រតិបត្តិ ប្រកបដោយសេចក្តីសន្ដោស និងការគោរព ទទួលបានយុត្តិធ៌ និងដំណោះស្រាយភ្លាមៗ ទទួលបានព័ត៌មាន ត្រូវបានគេស្តាប់ ហើយទស្សនយល់ឃើញរបស់ពួកគេ ត្រូវបានយកទៅធ្វើការពិចារណា នៅដំណាក់កាលសមស្រប ទទួលបានជំនួយសមស្របក្នុងដំណើរការច្បាប់ទាំងមូល។

សៀវភៅណែនាំរបស់ អង្គការអន្តរជាតិទេសន្តរប្រវេសន៍(IOM) ស្តីពីការផ្តល់ជំនួយផ្ទាល់ដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស (២០០៧) រំលេចឱ្យឃើញពីសារៈសំខាន់នៃគោលការណ៍មិនបង្កគ្រោះថ្នាក់ដែលជាគោលការណ៍ជាមូលដ្ឋានសម្រាប់អនុវត្តនៅពេលធ្វើការងារជាមួយជនដែលត្រូវបានជួញដូរ។ សៀវភៅនេះលើកឡើងថា អ្នកដែលធ្វើការជាមួយជន រងគ្រោះនៃអំពើជួញដូរមនុស្ស មានការទទួលខុសត្រូវផ្នែកក្រមសីលធម៌ ក្នុងការវាយតម្លៃឱ្យបានត្រឹមត្រូវ និងហ្មត់ចត់លើលទ្ធភាពដែលគ្រោះថ្នាក់អាចកើតមានឡើង ពាក់ព័ន្ធនឹងសកម្មភាពដែលពួកគេស្នើអនុវត្ត។ សៀវភៅសមាហរណកម្មរបស់អង្គការអន្តរជាតិទេសន្តរប្រវេសន៍(IOM)ផ្តល់ការណែនាំជាក់ស្តែងលើការរចនា ការអនុវត្ត និងការត្រួតពិនិត្យជំនួយក្នុងការធ្វើសមាហរណកម្ម ២០១៩។

### ៤.៣.២.ក្របខ័ណ្ឌអាស៊ាន

អនុសញ្ញាអាស៊ានប្រឆាំងអំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ តម្រូវឱ្យរដ្ឋជាសមាជិកអាស៊ានគោរពនិងការពារសិទ្ធិមនុស្សរបស់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស។ មាត្រា១៤ស្តីពីការការពារជនរងគ្រោះនៃអំពើជួញដូរមនុស្ស តម្រូវឱ្យប្រទេសជាសមាជិកអាស៊ានរៀបចំគោលការណ៍ណែនាំអំពីប្រធានបទជាច្រើន ដូចជាការកំណត់អត្តសញ្ញាណជនរងគ្រោះនៃអំពើជួញដូរមនុស្សឱ្យបានត្រឹមត្រូវ ការផ្តល់សុវត្ថិភាពរូបវន្តដល់ជនរងគ្រោះ ការការពារឯកជនភាព និងអត្តសញ្ញាណរបស់ជនរងគ្រោះ ការមិនចោទប្រកាន់ជនរងគ្រោះពីបទព្រហ្មទណ្ឌចំពោះទង្វើខុសច្បាប់ដែលពួកគេបានប្រព្រឹត្ត មិនដាក់ជនរងគ្រោះនៅកន្លែងឃុំឃាំង ឬពន្ធនាគារ ការផ្តល់សំណងចំពោះការខូចខាត ការផ្តល់សេវាថែទាំ និងការគាំទ្រទៅតាមការចាំបាច់។ល។

គោលការណ៍ណែនាំស្តីពីការធ្វើការងារជាមួយស្ត្រីដែលរងគ្រោះដោយសារអំពើជួញដូរមនុស្ស ដោយមានការយកចិត្តទុកដាក់អំពីយេនឌ័ររបស់អាស៊ាន ផ្តល់ជាអនុសាសន៍ថា "មុនពេលដែលមានការធ្វើសកម្មភាពអ្វីមួយគួរមានការពិចារណា ដើម្បីធានាឱ្យមានការកាត់បន្ថយជាអប្បរមានូវគ្រោះថ្នាក់គ្រប់ប្រភេទទាំងអស់ដែលអាចកើតឡើងចំពោះជនរងគ្រោះ។ គោលការណ៍ណែនាំនេះ បានអំពាវនាវឱ្យមានការរក្សាការសម្ងាត់ និងការផ្តល់ការយល់ព្រមត្រឹមត្រូវ គ្រប់ជ្រុងជ្រោយនៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការជួយដល់ជនរងគ្រោះ។

គោលការណ៍ណែនាំនេះអំពាវនាវឱ្យជនរងគ្រោះអាចចូលរួមប្រកបដោយអត្ថន័យក្នុងការធ្វើផែនការនិងការអនុវត្ត ជំនួយនានា ហើយអ្នកផ្ដល់សេវាត្រូវដឹងពីតម្រូវការ និងការបារម្ភពិសេសនានារបស់ស្ត្រី និងកុមារ។

គោលការណ៍ណែនាំ និងនីតិវិធីថ្នាក់តំបន់ ដើម្បីឆ្លើយតបចំពោះតម្រូវការរបស់ជនរងគ្រោះនៃអំពើជួញដូរមនុស្សរបស់គណៈកម្មការអាស៊ានទទួលបន្ទុកលើកកម្ពស់និងការពារសិទ្ធិស្ត្រីនិងកុមារ( ACWC )អំពាវនាវឱ្យរដ្ឋជាសមាជិកអាស៊ានដាក់ឱ្យអនុវត្តនូវយន្តការ និងនីតិវិធីដើម្បីសម្របសម្រួលដល់ការកំណត់អត្តសញ្ញាណជនរងគ្រោះឱ្យបានត្រឹមត្រូវនិងទាន់ពេលវេលា។ គោលការណ៍ណែនាំនេះក៏បានអំពាវនាវឱ្យការផ្ដល់ការគាំទ្រ និងការការពារចំពោះមុខ បើទោះជាជនរងគ្រោះពុំមានឆន្ទៈចូលរួមក្នុងនីតិវិធីច្បាប់ក៏ដោយ។ គោលការណ៍ណែនាំនេះ ក៏មានបញ្ចូលកិច្ចការពារជនរងគ្រោះមិនឱ្យទទួលរងគ្រោះថ្នាក់បន្ថែមទៀត ការពារឯកជនភាព ការផ្ដល់ជំនួយនានា និងការគាំទ្រដែលត្រូវការជាបន្ទាន់ឆ្លើយតបចំពោះស្ថានភាពច្បាប់របស់ជនរងគ្រោះជាជនបរទេស និងការពារជនរងគ្រោះពីការឃុំខ្លួន និងចោទប្រកាន់ទោស។

គោលការណ៍ណែនាំសម្រាប់អ្នកជំនាញអាស៊ាន ការឆ្លើយតបនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌចំពោះករណីនៃអំពើជួញដូរមនុស្ស ផ្ដល់អនុសាសន៍ឱ្យជនរងគ្រោះស្វែងរក និងទទួលបានដំណោះស្រាយ និងទទួលបានការការពារក៏ដូចជាជម្រកសុវត្ថិភាពទាន់ពេលវេលា និងទទួលបានការកាពារពីការតបតសងសឹកពីអ្នកដែលប្រព្រឹត្តអំពើជួញដូរពួកគេ។ គោលការណ៍ណែនាំនេះ ក៏អំពាវនាវឱ្យការអនុវត្តនីតិវិធីព្រហ្មទណ្ឌសម្រាប់សំណុំរឿងជួញដូរធ្វើឡើងឱ្យបានឆាប់រហ័សដើម្បីកាត់បន្ថយស្ត្រេស និងសម្ពាធរបស់ជនរងគ្រោះ។

សេចក្ដីប្រកាសរបស់អាស៊ានស្ដីពីសិទ្ធិរបស់កុមារក្នុងបរិបទទេសន្តរប្រវេសន៍ យល់ស្របឱ្យរដ្ឋជាសមាជិកអាស៊ានទាំងអស់ រៀបចំជានីតិវិធីប្រកបដោយប្រសិទ្ធភាព និងផ្ដល់ជម្រើសផ្សេងក្រៅពីការឃុំខ្លួនកុមារដែលធ្វើអន្តោប្រវេសន៍ដើម្បីកាត់បន្ថយផលប៉ះពាល់ និងធានាថា ក្នុងករណីដែលអាចធ្វើទៅបាន ត្រូវមានការរក្សាទុកកុមារឱ្យនៅជួបជុំជាមួយគ្រួសាររបស់ពួកគេនៅក្រៅកន្លែងឃុំឃាំង និងក្នុងមជ្ឈដ្ឋានដែលមានអនាម័យ និងសុវត្ថិភាព។ សេចក្ដីប្រកាសស្ដីពីសិទ្ធិមនុស្សរបស់អាស៊ាន បញ្ជាក់ពីសិទ្ធិស្ត្រី កុមារ យុវជន មនុស្សចាស់ ជនមានពិការភាព ពលករទេសន្តរប្រវេសន៍ និងក្រុមងាយរងគ្រោះ និងបាត់បង់ឱកាសថាជាផ្នែកដ៏សំខាន ដែលមិនអាចកាត់ផ្ដាច់ និងបំបែកពីសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន។

## ៤.៤.ក្រមសីលធម៌វិជ្ជាជីវៈកម្លាំងសេវាសង្គម

កម្លាំងសេវាសង្គមវិជ្ជាជីវៈ ប្រកាន់ខ្ជាប់នូវគោលការណ៍យុត្តិធម៌សង្គម សិទ្ធិមនុស្ស ការទទួលខុសត្រូវជាសមូហភាពនិងការគោរពនូវភាពចម្រុះជាមូលដ្ឋានគ្រឹះនិងផ្សារភ្ជាប់ប្រជាជនជាមួយរចនាសម្ព័ន្ធសង្គមដើម្បីដោះស្រាយបញ្ហាជីវិត និងលើកកម្ពស់សុខុមាលភាព ដោយផ្អែកលើទ្រឹស្ដីសង្គមកិច្ចវិទ្យា សង្គមសាស្ត្រ មនុស្សសាស្ត្រ និងចំណេះដឹងនានាពីជាតិពិន្ទុ។ កម្លាំងសេវាសង្គមត្រូវគោរពនិងអនុវត្តក្រមសីលធម៌វិជ្ជាជីវៈ[3]ដូចខាងក្រោម៖

### ៤.៤.១.គុណតម្លៃនិងគោលការណ៍

### ក. សេចក្ដីថ្លៃថ្នូរ និងសិទ្ធិឯកជនភាព

- ត្រូវគោរពសិទ្ធិជាមូលដ្ឋាន និងសេចក្ដីថ្លៃថ្នូរពីកំណើតរបស់បុគ្គលគ្រប់រូប ហើយបង្ហាញនូវការទទួលយកដោយឥតលក្ខខណ្ឌ

[3] ប្រកាសលេខ ២១៤ ស.អ.យ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៣ ស្ដីពីក្រមសីលធម៌វិជ្ជាជីវៈកម្លាំងសេវាសង្គម

- ត្រូវចាត់ទុកអតិថិជនជាមនុស្សដែលមានតម្លៃ ដោយមិនគិតពីប្រវត្តិ ឬបញ្ហារបស់ពួកគាត់
- ត្រូវរក្សាការសម្ងាត់ និងការពារសិទ្ធិឯកជនភាពរបស់អតិថិជន ទាំងអត្តសញ្ញាណ និងកំណត់ត្រាផ្ទាល់ខ្លួនជាការសម្ងាត់(រួមទាំងតាមប្រព័ន្ធអេឡិចត្រូនិក)លើកលែងតែក្នុងករណីចាំបាច់ដើម្បីឧត្តមប្រយោជន៍ អតិថិជន និងសុវត្ថិភាព សាធារណៈតែប៉ុណ្ណោះដូចជា៖
    - ផ្តល់កិច្ចគាំទ្របច្ចេកទេស ឬការពិគ្រោះយោបល់
    - រាយការណ៍រាល់ការរំលោភបំពានតាមតម្រូវការផ្នែកច្បាប់
    - ក្នុងករណីបន្ទាន់ ដើម្បីការពារអតិថិជន ឬអ្នកផ្សេងទៀតពីគ្រោះថ្នាក់ធ្ងន់ធ្ងរ ឬពីការស្លាប់
    - បទឧក្រិដ្ឋធ្ងន់ធ្ងរបានកើតឡើង ដូចមានចែងក្នុងក្រមព្រហ្មទណ្ឌ
- ត្រូវរក្សាការសម្ងាត់របស់អតិថិជននៅតាមប្រព័ន្ធអេឡិចត្រូនិចនិងតាមបណ្តាញសង្គមនានាដូចជាសារព័ត៌មានជាដើម
- ត្រូវប្រកាន់ខ្ជាប់តាមកិច្ចសន្យាក្នុងការរក្សាការសម្ងាត់របស់ស្ថាប័នដែលខ្លួនបម្រើការ និងគោលការណ៍រក្សាការសម្ងាត់របស់ស្ថាប័ន។

**ខ.ភាពជាបុគ្គល**

- ត្រូវចាត់ទុកមនុស្សម្នាក់ៗថាមានលក្ខណៈពិសេសប្លែកៗគ្នារៀងៗខ្លួន ហើយខិតខំស្វែងយល់ពីភាពខ្លាំងនិងបញ្ហាប្រឈម (អតិថិជន)
- ត្រូវបង្កលក្ខណៈងាយស្រួលដល់អតិថិជន ក្នុងការទទួលយកសេវាទៅតាមតម្រូវការរបស់អតិថិជនម្នាក់ៗ ដោយផ្អែកតាមកាលៈទេសៈ ភាពខ្លាំង និងតម្រូវការជាក់ស្តែង
- ត្រូវចៀសវាងការធ្វើបុរេវិនិច្ឆ័យលើបុគ្គល ឬក្រុមមនុស្សណាមួយ ដោយផ្អែកលើកត្តាមួយចំនួនដូចជាជាតិ-សាសន៍ យេនឌ័រ ជាតិពិន្ទុ វប្បធម៌ ស្ថានភាពរងគ្រោះ ភាពក្រីក្រ សាសនា អត្តសញ្ញាណភេទ ពិការភាព កម្រិតវប្បធម៌ ឬមុខរបររបស់អតិថិជន។

**គ.ការមិនរើសអើង**

- ត្រូវទទួលស្គាល់នូវភាពលម្អៀង និងបុរេវិនិច្ឆ័យរបស់ខ្លួន ហើយព្យាយាមជំនះឱ្យបាន ដើម្បីកុំឱ្យជះឥទ្ធិពល មិនល្អដល់ការអនុវត្តសេវាសង្គម
- ត្រូវបង្ហាញការគោរព និងក្តីសណ្តោសចំពោះមនុស្សគ្រប់រូប ដើម្បីឱ្យពួកគេមានអារម្មណ៍កក់ក្តៅនិងយល់ថាខ្លួនមានតម្លៃ
- មិនត្រូវផ្តល់នូវសេវាដែលមានគុណភាពខុសគ្នា ឬបរិមាណខុសគ្នាដល់អតិថិជន ដោយសារតែកត្តាជាតិសាសន៍ យេនឌ័រ ជាតិពិន្ទុ វប្បធម៌ ស្ថានភាពរងគ្រោះ ភាពក្រីក្រ សាសនា អត្តសញ្ញាណភេទ ពិការភាព កម្រិតវប្បធម៌ ឬមុខរបរនោះឡើយ
- ត្រូវយកចិត្តទុកដាក់ និងស្មោះត្រង់ក្នុងការបំពេញការងារ ដោយមិនប្រកាន់ថា អតិថិជនមានស្ថានភាពបែបណាឡើយ។

**ឃ.ការយល់ដឹងពីវប្បធម៌**

- ត្រូវទទួលស្គាល់ថាខ្លួនឯងមិនអាចយល់ច្បាស់ពីស្ថានភាពទាំងអស់របស់អ្នកដទៃបានទេ ជាពិសេសប្រសិនបើបុគ្គលម្នាក់ៗមាន វប្បធម៌ សាសនា ឬតំបន់ និងភូមិសាស្ត្រខុសគ្នា

- ឈ្វេងយល់ពីស្ថានភាពជីវិតរបស់អតិថិជនតាំងពីពេលចាប់កំណើតរហូតមកដល់បច្ចុប្បន្ននិងក្តីសង្ឃឹមរបស់អតិថិជននាពេលអនាគត
- ត្រូវចង់ចេះ ចង់ដឹងពីក្រុមមនុស្សដែលមានប្រភពផ្សេងៗគ្នា ដោយប្រកាន់យកនូវឥរិយាបថសុភាពរាបសារ ស្រគត់ស្រគំ មិនក្រអឺតក្រទម និងមានសណ្តានចិត្តទូលាយ
- ត្រូវឈ្វេងយល់ពីទស្សនៈរបស់បុគ្គលម្នាក់ៗចំពោះស្ថានភាពជីវិតខ្លួនគេដែលជារឿយៗច្រើនមានការយល់ឃើញខុសពីខ្លួនយើងជាអ្នកផ្តល់សេវា។

**ង.សេវាកម្ម**

- ត្រូវប្រកាន់ខ្ជាប់នូវឧត្តមប្រយោជន៍របស់អតិថិជនធំជាងផលប្រយោជន៍ផ្ទាល់ខ្លួន
- ត្រូវទទួលខុសត្រូវក្នុងការផ្តល់នូវសេវាសមស្របនិងមិនគិតពីឥរិយាបថរបស់អតិថិជនដែលធ្វើចំពោះខ្លួន
- ត្រូវកំណត់ព្រំដែនឱ្យបានច្បាស់រវាងការផ្តល់សេវាជូនអតិថិជននិងការធ្វើសកម្មភាពជំនួសអតិថិជន
- ត្រូវកំណត់ភាពចន្លោះប្រហោង ឬភាពខ្វះខាតលើផ្នែកសេវាកម្ម ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ហើយត្រូវសហការជាមួយអ្នកពាក់ព័ន្ធ ដើម្បីកែលម្អសេវាកម្មទាំងនោះតាមការចាំបាច់។

**ច.យុត្តិធម៌សង្គម**

- ត្រូវទទួលស្គាល់ថា មានក្រុមជនដែលទទួលរងការរើសអើង មាក់ងាយ ឬមានស្លាកស្នាមជិតដាមនិងមិនទទួលបាននូវឱកាសស្មើគ្នា
- អាចពន្យល់អំពីស្ថានភាពនៃយុត្តិធម៌សង្គម និងខិតខំលុបបំបាត់ការរើសអើង នៅតាមសហគមន៍ ក្នុងកន្លែងធ្វើការ និងនៅក្នុងស្ថាប័ន អង្គភាពនានា
- ត្រូវផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើអ្នកដែលមានភាពងាយរងគ្រោះដូចជា កុមារ ជនមានពិការភាព យេនឌ័រ វ័យចាស់ និងអ្នកដែលមានតម្រូវការពិសេសផ្សេងទៀត
- ត្រូវស្វែងរកការគាំទ្រ និងការលើកកម្ពស់សិទ្ធិរបស់ជនរងគ្រោះដោយមិនរើសអើង និងបង្កើនឱកាសសម្រាប់អ្នកដែលជួបការលំបាកទាំងនោះ។

**ឆ.ការចូលរួមរបស់អតិថិជន**

- ត្រូវលើកទឹកចិត្តនិងផ្តល់ឱកាសឱ្យអតិថិជនចូលរួមដោយពេញលេញនៅគ្រប់ដំណាក់កាលនៃទំនាក់ទំនងការងារ
- ត្រូវគោរពមតិយោបល់របស់អតិថិជន ជាពិសេសអ្នកដែលងាយរងគ្រោះបំផុត ដូចជា កុមារ ជនមានពិការភាព យុវជន ស្ត្រី ក្រុមមនុស្សស្រលាញ់ភេទដូចគ្នា និងក្រុមមនុស្សដែលមានចំណេះដឹងតិចតួចជាដើម។ល។
- ត្រូវផ្តល់ព័ត៌មានអំពីលទ្ធផលដែលអាចកើតពីការសម្រេចចិត្តរបស់គាត់ ហើយគោរពតាមការសម្រេចចិត្តរបស់អតិថិជនពាក់ព័ន្ធនឹងគោលដៅផ្ទាល់ខ្លួនរបស់គាត់ ដរាបណាវាមិនបង្កគ្រោះថ្នាក់ដល់អតិថិជន ឬអ្នកដទៃ។

**ជ.ការពង្រឹងសិទ្ធិអំណាច**

- ត្រូវជួយអតិថិជនឱ្យយល់ថា គាត់អាចដោះស្រាយបញ្ហាផ្ទាល់ខ្លួនបានតាមរយៈការប្រើប្រាស់គុណតម្លៃ និងក្រមសីលធម៌សេវាសង្គម

- ត្រូវមានការលើកទឹកចិត្ត សរសើរដល់អតិថិជន ចំពោះការខិតខំធ្វើឱ្យស្ថានភាពរបស់ពួកគាត់មានភាពរីកចម្រើនល្អប្រសើរឡើង ដោយមិនលើកសរសើរខ្លួនឯង
- ត្រូវពន្យល់ពីដំណើរការនៃការជួយដល់អតិថិជនជាបន្តបន្ទាប់ ធ្វើយ៉ាងណាឱ្យអតិថិជនមានភាពម្ចាស់ការ និងមិនពឹងផ្អែកលើអ្នកផ្តល់ជំនួយ
- ត្រូវជួយឱ្យអតិថិជនយល់ថា អ្នកផ្តល់សេវា គឺជាអ្នកសហការដែលមានជំនាញវិជ្ជាជីវៈ មិនមែនជាអ្នកមានអំណាចលើអតិថិជននោះទេ។

**ឈ.សមត្ថភាព**

- ត្រូវចូលរួមចំណែកតែក្នុងការងារណាដែលខ្លួនមានចំណេះដឹង បទពិសោធន៍ និងជំនាញគ្រប់គ្រាន់ក្នុងការបំពេញកិច្ចការប្រកបដោយគុណភាពនិងប្រសិទ្ធភាពប៉ុណ្ណោះ
- ត្រូវខិតខំអភិវឌ្ឍនិងពង្រឹងសមត្ថភាពជំនាញខ្វះខាតមុនពេលបំពេញការងារ ឬចំណេះដឹងអំពីការងារណាមួយបន្ថែមទៀត ដែលត្រូវបន្តកសាងសមត្ថភាព និងជំនាញឱ្យបានលើសពីចំណេះដឹង និងជំនាញដែលមាន
- ត្រូវបំពេញការងារដោយប្រើប្រាស់វិធីសាស្ត្រដែលវិជ្ជាជីវៈទទួលស្គាល់។

**ញ.សុចរិតភាព និងគណនេយ្យភាព**

- ត្រូវមានភាពស្មោះត្រង់ និងទទួលស្គាល់កំហុសឆ្គងរបស់ខ្លួនក្នុងការបំពេញការងារ ហើយខិតខំរិះរកវិធីកែលម្អដើម្បីធានានូវការមិនបង្កការឈឺចាប់ដល់អតិថិជន ឬអ្នកដទៃ
- ត្រូវដឹងពីស្ថានភាពនៃទំនាស់ផលប្រយោជន៍ និងត្រូវចៀសវាងពីទំនាស់ផលប្រយោជន៍ ឬត្រូវចូលរួមដោះស្រាយទំនាស់ទាំងនោះ តាមរយៈការឆ្លុះបញ្ចាំងផ្ទាល់ខ្លួន និងជំនួយគាំទ្របច្ចេកទេស
- ត្រូវប្រាស្រ័យទាក់ទងគ្នាដោយតម្លាភាពជាមួយអតិថិជននិងសហការី ស្របតាមបរិបទការងាររបស់ខ្លួន។

**ដ.ការប្តេជ្ញាចិត្ត និងការលះបង់**

- ត្រូវប្តេជ្ញាចិត្ត និងមានឆន្ទៈក្នុងការផ្តល់សេវាជូនអតិថិជន តាមរយៈការចុះជួបជាទៀងទាត់ និងបន្តតាមដាន ជាប្រចាំគ្រប់ករណី
- ត្រូវចាត់ទុកតម្រូវការរបស់អតិថិជនជាអាទិភាពឱ្យខ្ពស់ជាងការងារដែលជាចំណង់ចំណូលចិត្តរបស់ខ្លួន
- ត្រូវជួយឱ្យអតិថិជនមានជំនឿជឿជាក់ថា គាត់គឺជាអ្នកសហការពិតប្រាកដ ក្នុងការធ្វើឱ្យមានការផ្លាស់ប្តូរក្នុងជីវិត
- ត្រូវគោរពពេលវេលា ផ្តោតការយកចិត្តទុកដាក់លើអតិថិជន និងធ្វើតាមអ្វីដែលខ្លួនបានប្តេជ្ញាចិត្តជាមួយគាត់។

**ឋ.ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា និងបណ្តាញសង្គម**

- ត្រូវទទួលស្គាល់ថាការប្រើប្រាស់ប្រព័ន្ធឌីជីថល និងបណ្តាញសង្គម អាចបង្កការគំរាមកំហែងដល់ការអនុវត្តក្រមសីលធម៌ជាច្រើនរួមមានជាអាទិ៍ ឯកជនភាព និងរក្សាការសម្ងាត់ ទំនាស់ផលប្រយោជន៍ សមត្ថភាព និងកំណត់ត្រាឯកសារ ហើយត្រូវមានចំណេះដឹងនិងជំនាញចាំបាច់នានា ដើម្បីត្រួតពិនិត្យការអនុវត្តដែលមិនស្របតាមក្រមសីលធម៌នៅពេលប្រើប្រាស់បច្ចេកវិទ្យា។

### ៤.៤.២.ក្រមសីលធម៌កម្លាំងសេវាសង្គម

#### ក.ចំពោះខ្លួនឯង

- ត្រូវគោរពនូវសិទ្ធិ គុណតម្លៃ និងសេចក្ដីថ្លៃថ្នូររបស់មនុស្ស ដោយមិនប្រកាន់អំពីជំនឿ សាសនា ភាសា ភេទ អាយុ ធនធាន វប្បធម៌ ពូជសាសន៍ ពណ៌សម្បុរ ឋានៈសង្គម និន្នាការនយោបាយនិងស្ថានភាពឯទៀតនៃការផ្ដល់សេវា ដើម្បីធានាថាជនរងគ្រោះ និងងាយរងគ្រោះ និងភាគីពាក់ព័ន្ធទទួលបានព័ត៌មាន និងចូលរួមក្នុងដំណើរការនៃការសម្រេចចិត្ត។
- មិនត្រូវធ្វើបុរេវិនិច្ឆ័យជនរងគ្រោះ និងងាយរងគ្រោះដោយគ្មានមូលដ្ឋាននៃការវាយតម្លៃពីអ្នកវិជ្ជាជីវៈ ដើម្បីកុំឱ្យជះឥទ្ធិពលមិនល្អដល់ការអនុវត្តសេវាសង្គមកិច្ច។
- ត្រូវរក្សាការសម្ងាត់វិជ្ជាជីវៈក្នុងលក្ខខណ្ឌដែលបានកំណត់ដោយច្បាប់ និងបទបញ្ញត្តិនានាដើម្បីឧត្តមប្រយោជន៍របស់ជនរងគ្រោះ និងងាយរងគ្រោះ។
- កម្លាំងសេវាសង្គមត្រូវប្ដេជ្ញាចិត្តជានា យុត្តិធម៌សង្គម និងសិទ្ធិមនុស្សតាមរយៈ៖
  - ការលើកកម្ពស់ការអនុវត្តច្បាប់ គោលនយោបាយ បទដ្ឋានគតិយុត្តផ្សេងៗ និងល័ក្ខខ័ណ្ឌសង្គមប្រកបដោយសមធម៌ និងសមភាព
  - គោរព និងទទួលស្គាល់ភាពចម្រុះគ្នា
  - ផ្ដល់សិទ្ធិអំណាចដល់បុគ្គល គ្រួសារ និងសហគមន៍
  - ធ្វើការវិភាគបញ្ហា តម្រូវការសង្គម និងធ្វើផែនការឆ្លើយតប
  - រក្សាការស្គាល់ខ្លួនឯង និងថែទាំខ្លួនឯងជានិច្ច
- មិនត្រូវផ្ដល់ការសម្របសម្រួលណាមួយ ដែលនាំឱ្យខ្លួនប្រព្រឹត្តផ្ទុយនឹងច្បាប់និងបទបញ្ជាឡើយ។
- ត្រូវជៀសវាងការប្រព្រឹត្តអំពើទាំងឡាយណាដែលធ្វើឱ្យអាប់ឱនដល់កិត្តិយសនិងវិជ្ជាជីវៈរបស់ខ្លួន មានដូចជា៖
  - កេងប្រវ័ញ្ចលើផលប្រយោជន៍ដែលផ្ដើមចេញពីទំនាក់ទំនងវិជ្ជាជីវៈណាមួយ (តាមរយៈសាសនា នយោបាយ ឬមុខជំនួញជាដើម)
  - មានទំនាក់ទំនងពីរ ឬច្រើនជាមួយជនរងគ្រោះ និងងាយរងគ្រោះ (ក្រៅពីទំនាក់ទំនងអាជីព) ដែលអាចមានហានិភ័យនៃការកេងប្រវ័ញ្ច
  - មិនត្រូវមានទំនាក់ទំនងរាងកាយ ជាមួយជនរងគ្រោះ និងងាយរងគ្រោះនោះទេ ដូចជា ការប៉ះពាល់រាងកាយ (ថើប អង្អែល...) ដែលអាចជាការបង្ហាញការយកចិត្តទុកដាក់ជ្រុល ឬអាចជាការរំខាន នាំឱ្យមានការប៉ះពាល់ផ្លូវចិត្តរបស់ពួកគេ។
  - បើទោះជាក្នុងស្ថានភាពណាក៏ដោយ កម្លាំងសេវាសង្គមមិនត្រូវមានទំនាក់ទំនងផ្លូវភេទជាមួយជនរងគ្រោះ និងងាយរងគ្រោះដែលកំពុងមកទទួលសេវា ទោះបើជាជនរងគ្រោះ និងងាយរងគ្រោះយល់ព្រម ឬមិនយល់ព្រមក៏ដោយ
  - មិនត្រូវមានទំនាក់ទំនងផ្លូវភេទជាមួយសាច់ញាតិរបស់ជនរងគ្រោះ និងងាយរងគ្រោះ ឬមិត្តភក្តិរបស់ជនរងគ្រោះ និងងាយរងគ្រោះឡើយ

- ○ មិនត្រូវមានទំនាក់ទំនងផ្លូវភេទជាមួយ អតីតជនរងគ្រោះ និងងាយរងគ្រោះឡើយពីព្រោះវាអាចបង្កទុក្ខទោសដល់ជនរងគ្រោះ និងងាយរងគ្រោះ។

- ត្រូវអនុវត្តការងាររបស់ខ្លួនប្រកបដោយវិជ្ជាជីវៈ និងមានការទទួលស្គាល់ពីស្ថាប័នជំនាញវិជ្ជាជីវៈសង្គមកិច្ចរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។
- ត្រូវស្វ័យសិក្សា ស្រាវជ្រាវសម្រិតសម្រាំង បង្កើនចំណេះដឹងរបស់ខ្លួន និងចូលរួមគ្រប់សកម្មភាពអភិវឌ្ឍន៍សមត្ថភាព ជំនាញវិជ្ជាជីវៈថ្មីៗជាប្រចាំ និងធ្វើបច្ចុប្បន្នភាពជាប្រចាំចំពោះចំណេះដឹងនិងជំនាញរបស់ខ្លួនតាមរយៈការអភិវឌ្ឍវិជ្ជាជីវៈ រួមទាំងហាត់អនុវត្តជាប្រចាំ ដើម្បីធានាបាននូវសង្គតិភាព និងការផ្តល់សេវាប្រកបដោយគុណភាព តម្លាភាព គណនេយ្យភាព និងទាន់ពេលវេលា សម្រាប់ខ្លួនឯង ជនរងគ្រោះ និងងាយរងគ្រោះឱ្យទទួលបាននូវសុខុមាលភាព និងរួមទាំងទទួលយកនូវព័ត៌មានត្រឡប់នានា សម្រាប់ធ្វើការកែលម្អ និងផ្លាស់ប្តូរផងដែរ។
- ត្រូវប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈ ក្នុងការអនុវត្តមុខងាររបស់ខ្លួន និងការផ្តល់សេវាដល់ជនរងគ្រោះ និងងាយរងគ្រោះ ដើម្បីធានាថា គ្មានការប្រើអំណាច កេងប្រវ័ញ្ច រំលោភបំពានបំពានសិទ្ធិ ទំនាស់ផលយោជន៍ និងសកម្មភាពទាំងឡាយណាដែលផ្ទុយនឹងច្បាប់រដ្ឋ។
- ត្រូវប្រើឥរិយាបថ និងពាក្យសម្តីដោយប្រុងប្រយ័ត្ន និងគិតដល់ប្រតិឃាតនៃពាក្យសម្តីរបស់ខ្លួនចំពោះជនរងគ្រោះ និងងាយរងគ្រោះ និងសាធារណៈជនក្នុងការផ្តល់ព័ត៌មានអំពីការផ្តល់សេវាទាំងសាធារណៈ ទាំងឯកជនតាមគ្រប់មធ្យោបាយផ្សព្វផ្សាយ។ ចូលរួមក្នុងសកម្មភាពក្នុងស្ថាប័នវិជ្ជាជីវៈដើម្បីរៀនសូត និងចែករំលែកពីបទពិសោធន៍ក្នុងគោលដៅធ្វើឱ្យចម្រើនដល់វិជ្ជាជីវៈ និងអតិថិជន។
- ត្រូវអនុវត្តដោយផ្អែកលើទ្រឹស្តីសង្គមកិច្ច ការស្រាវជ្រាវពាក់ព័ន្ធទ្រឹស្តីសង្គមផ្សេងទៀត បទពិសោធន៍ជាក់ស្តែង ហើយជៀសវាងផ្តល់ការអន្តរាគមន៍ដោយភាពប្រថុយប្រថាន ឬបើគ្មានជំនាញច្បាស់លាស់ ឬអនុវត្តដោយស្ថិតនៅក្រោមសម្ពាធដែលមិនសមស្របតាមវិជ្ជាជីវៈ។ មិនប្រព្រឹត្តអំពើពុករលួយ ឬក៏បកេងគ្រប់ប្រភេទ និងមិនធ្វើការកេងប្រវ័ញ្ចលើអតិថិជន ឬស្ថាប័នក្នុងរូបភាពណាមួយដើម្បីផលប្រយោជន៍ខ្លួនឯងឡើយ។

**ខ.ចំពោះអតិថិជន (ជនរងគ្រោះនិងងាយរងគ្រោះ)**

- ត្រូវធានានូវការគោរពសិទ្ធិ និងឧត្តមប្រយោជន៍របស់ជនរងគ្រោះ និងងាយរងគ្រោះ ដោយធានានូវការពារសុវត្ថិភាព ការផ្តល់អាទិភាពជាចម្បង និងការផ្តល់សេវាសមស្រប ដោយប្រើប្រាស់យន្តការកិច្ចសហប្រតិបត្តិការជាអន្តរវិស័យក្នុងការបង្ការទប់ស្កាត់ អន្តរាគមន៍ ដោះស្រាយ និងឆ្លើយតប ដោយអនុវត្តនូវវិធីសាស្ត្រយកជនរងគ្រោះ និងងាយរងគ្រោះជាធំ និងគិតពីឧត្តមប្រយោជន៍ (សម្រាប់កុមារ)
- ត្រូវសម្របសម្រួលក្នុងការលើកកម្ពស់ ការប្តេជ្ញាចិត្ត និងស្វ័យភាពឱ្យស្របទៅតាមតម្រូវការរបស់អតិថិជន(ជនរងគ្រោះ និងងាយរងគ្រោះ)ដោយមិនបង្កគ្រោះថ្នាក់ដល់អាយុជីវិតខ្លួនឯងនិងអ្នកដទៃ។
- ត្រូវកំណត់ព្រំដែនរបស់ខ្លួន ជាមួយអតិថិជន(ជនរងគ្រោះ និងងាយរងគ្រោះ)ពិសេសកុមារ ដូចជា៖ បញ្ហាភេទ គម្លាតនៃការអង្គុយ ទីកន្លែងជួបសន្ទនា (កន្លែងស្ងាត់ដែលអ្នកដទៃមិនអាចស្តាប់ឮ តែអ្នកដទៃអាចមើលឃើញ)។

- ត្រូវគោរពសិទ្ធិឯកជន និងរក្សាការសម្ងាត់អំពីព័ត៌មានរបស់ជនរងគ្រោះ និងងាយរងគ្រោះ ក្នុងការប្រើប្រាស់ព័ត៌មានដែលទទួលបាន ប្រកបដោយការទទួលខុសត្រូវស្របតាមក្រមសីលធម៌វិជ្ជាជីវៈនេះ និងវិជ្ជាជីវៈដទៃទៀតជាធរមាន។
- ត្រូវទទួលស្គាល់នូវលក្ខណៈពិសេសផ្សេងៗគ្នា របស់ជនរងគ្រោះ ហើយត្រូវប្រព្រឹត្តចំពោះម្នាក់ៗថាជាបុគ្គលដែលមានលក្ខណៈពិសេសដោយឡែករៀងៗខ្លួនដោយៈ
  - មិនប្រើអំណាច ចំណេះដឹង ជំនាញ ជំនឿ ទស្សនៈ ដើម្បីដាក់សម្ពាធលើជនរងគ្រោះ និងងាយរងគ្រោះ ពិសេសកុមារ
  - ការប្រាស្រ័យទាក់ទងប្រកបដោយការគោរព និងឱ្យតម្លៃជនរងគ្រោះ និងងាយរងគ្រោះ
  - មិនវិនិច្ឆ័យ
  - មិនរើសអើង
  - ផ្តល់ភាពកក់ក្តៅឥតក្លែងក្លាយ (ប្រើពាក្យសម្តីទន់ភ្លន់ មិនស្តីបន្ទោស ដាក់កំហុស មិនគំរាមកំហែង។ល។)
  - មិនធ្វើតាមតម្រូវការរបស់ខ្លួន អង្គភាព ឬស្ថាប័ន។
- ត្រូវកត់ត្រានូវព័ត៌មានរបស់អតិថិជន (ជនរងគ្រោះនិងងាយរងគ្រោះ) ឱ្យបានត្រឹមត្រូវតាមប្រព័ន្ធគ្រប់គ្រងព័ត៌មាននិង/ឬកត់ត្រាដោយផ្ទាល់តាមទម្រង់គ្រប់គ្រងករណី ស្របតាមករណីនៃជំនាញនីមួយៗ។
- កម្លាំងសេវាសង្គម ត្រូវស្វែងរកការគាំទ្រ និងធ្វើកិច្ចសហការជាមួយភាគីពាក់ព័ន្ធ ដើម្បីធ្វើការវាយតម្លៃលទ្ធផល ការអនុវត្តផែនការសកម្មភាពឆ្លើយតបទៅនឹងតម្រូវការរបស់អតិថិជន(ជនរងគ្រោះ និងងាយរងគ្រោះ) មុននឹងធ្វើសេចក្តីសម្រេចចិត្តបិទករណី ឬ ត្រូវបញ្ជូនបន្តទៅទទួលសេវាកម្មផ្សេងទៀត។

**គ.ចំពោះកម្លាំងសេវាសង្គមដូចគ្នា និងវិជ្ជាជីវៈដទៃ**

- ត្រូវគោរពសិទ្ធិអ្នកមានអាជីពដូចគ្នា ដោយទទួលស្គាល់ និងចែករំលែកចំណេះដឹង និងបទពិសោធន៍ ព្រមទាំងផ្តល់នូវគុណតម្លៃមនុស្សជាតិ និងវប្បធម៌ក្នុងការបំពេញការងារ ដើម្បីសម្របសម្រួលសេវាកម្មដល់អតិថិជន (ជនរងគ្រោះ និងងាយរងគ្រោះ) ប្រកបដោយប្រសិទ្ធភាព។
- ត្រូវរក្សា និងបង្កើនទំនាក់ទំនងជាសហភាតរៈ និងមិនបង្កទំនាស់រវាងអ្នកមានវិជ្ជាជីវៈដូចគ្នា ក្នុងករណីមានទំនាស់កម្លាំងសេវាសង្គម ត្រូវសម្របសម្រួលគ្នាក្នុងស្មារតីសាមគ្គីភាព ដើម្បីរក្សាកិត្តិយស និងតម្លៃសង្គមរបស់អ្នកវិជ្ជាជីវៈ។
- ត្រូវមានភារកិច្ចក្នុងការជួយគាំទ្រអ្នកមានអាជីពដូចគ្នា នៅពេលជួបការលំបាកសម្រាប់ករណីរបស់អតិថិជន(ជនរងគ្រោះ និងងាយរងគ្រោះ)ណាមួយ ដោយធ្វើការពិភាក្សា ឬសន្និសីទករណី។
- ត្រូវបង្កើនការសហការ និងផ្តល់ការគាំទ្រដល់អ្នកអាជីពដទៃៗទៀត ក្នុងស្មារតីបំពេញតម្រូវការដល់អតិថិជន និងលើកកម្ពស់សុខុមាលភាពសង្គមទៅតាមភាពចាំបាច់ និងធ្វើការតស៊ូមតិជាមួយអ្នកមានវិជ្ជាជីវៈផ្សេងទៀតក្នុងករណីមានការអនុវត្តខុសឆ្គង ឬអាចប៉ះពាល់ដល់សុខុមាលភាពអតិថិជន។
- ត្រូវចាត់វិធានការសមស្របទៅតាមច្បាប់ជាតិ ឬគោលនយោបាយស្ថាប័នប្រសិនបើបានដឹងអំពីការប្រព្រឹត្តិខុសដោយមិត្តរួមអាជីព (ឧ.អំពើកឹបកេង)។

## ផ្នែកទី៥៖ នីតិវិធីទទួល និងគ្រប់គ្រងករណីជនរងគ្រោះ

### ៥.១.ការទទួលជនរងគ្រោះ ឬបុគ្គលសង្ស័យថារងគ្រោះផ្តល់សេវាសង្គមកិច្ច

មន្ត្រីទទួលបន្ទុកមន្ទីរ ស.អ.យ មន្ត្រីទទួលបន្ទុកថ្នាក់ជាតិ មន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ និងមន្ត្រី-បុគ្គលិកមជ្ឈមណ្ឌល មានភារកិច្ចទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ"**ក្នុងស្រុក**" ដែលបញ្ជូនមកពីមន្ត្រីនគរបាលយុត្តិធម៌ជំនាញ និងជនរងគ្រោះ ឬបុគ្គលសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទមកពី "**ក្រៅស្រុក**" តាមច្រកអន្តរជាតិនានា(**ផ្លូវអាកាស**[4]**ផ្លូវទឹក និងផ្លូវគោក**)ដែលបញ្ជូនមកពីស្ថានតំណាងកម្ពុជានៅក្រៅប្រទេសនិងតាមរយៈក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ដោយអនុវត្តជំហានតាមរូបភាពទី១ខាងក្រោម។

រូបភាពទី១៖ជំហាននៃការទទួលជនរងគ្រោះ ឬបុគ្គលសង្ស័យថារងគ្រោះផ្តល់សេវាសង្គមកិច្ច




**សំគាល់**-រូបភាពទី១៖ជំហាននៃការទទួលជនរងគ្រោះ ឬបុគ្គលសង្ស័យថារងគ្រោះផ្តល់សេវាសង្គមកិច្ច ភ្ជាប់ទៅរូបភាពទី២៖ជំហាននៃការគ្រប់គ្រងករណីជនរងគ្រោះដោយសារអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ។

---

[4] នីតិវិធីមាតុភូមិនិវត្តជនរងគ្រោះ ឬបុគ្គលសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្សតាមផ្លូវអាកាសមកកម្ពុជា។

**ជំហានទី១៖ការទទួលជនរងគ្រោះ និងសម្របសម្រួលការកំណត់អត្តសញ្ញាណ**

មន្ត្រីទទួលបន្ទុក មន្ទីរ ស.អ.យ មន្ត្រីទទួលបន្ទុក ថ្នាក់ជាតិ និង មន្ត្រី-បុគ្គលិក មជ្ឈមណ្ឌល មានភារកិច្ចទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ "**ក្នុងស្រុក**" និងជនរងគ្រោះ ឬបុគ្គលសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទមកពី "**ក្រៅស្រុក**" តាមច្រកអន្តរជាតិ (**ផ្លូវអាកាស ផ្លូវគោក និងផ្លូវទឹក**) ត្រូវអនុវត្តនីតិវិធីដូចខាងក្រោម៖

**<u>នីតិវិធីអនុវត្ត៖</u>**

១.១ មន្ត្រីទទួលបន្ទុកមន្ទីរ ស.អ.យ ឬ មន្ត្រីទទួលបន្ទុកថ្នាក់ជាតិ ត្រូវទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ "**ក្នុងស្រុក**" ពីមន្ត្រីនគរបាលយុត្តិធម៌ជំនាញបន្ទាប់ពីបានចុះបង្ក្រាបនិងសង្គ្រោះដោយភ្ជាប់មកជាមួយនូវ**ទម្រង់ទី៤៖កំណត់ហេតុប្រគល់-ទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ**(ឧបសម្ព័ន្ធទី១)។ ក្នុងករណីដែលបុគ្គលសង្ស័យថារងគ្រោះ ជាអនីតិជនគឺតម្រូវឱ្យមន្ត្រីទទួលបន្ទុកមន្ទីរ ស.អ.យ ឬមន្ត្រីទទួលបន្ទុកថ្នាក់ជាតិចូលរួមនៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌ជំនាញកំណត់អត្តសញ្ញាណ។

១.២ មន្ត្រីទទួលបន្ទុកមន្ទីរ ស.អ.យ ឬ មន្ត្រីទទួលបន្ទុកថ្នាក់ជាតិ ត្រូវទទួលជនរងគ្រោះ ឬបុគ្គលសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ មកពី"**ក្រៅស្រុក**"តាមច្រកអន្តរជាតិ (**ផ្លូវអាកាស ផ្លូវគោក និងផ្លូវទឹក**) តាមរយៈស្ថានតំណាងកម្ពុជានៅក្រៅប្រទេស ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សហការជាមួយសមត្ថកិច្ចប្រទេសគោលដៅ និងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ ធ្វើមាតុភូមិនិវត្តន៍មកប្រទេសវិញដោយភ្ជាប់មកជាមួយនូវ**ទម្រង់ទី១៖លិខិតបញ្ជូន និងលិខិតធ្វើដំណើរបណ្តោះអាសន្ន** (ឧបសម្ព័ន្ធទី១)។

១.៣ មន្ត្រីទទួលបន្ទុកមន្ទីរ ស.អ.យ ឬ មន្ត្រីទទួលបន្ទុកថ្នាក់ជាតិ ត្រូវបញ្ជូនជនរងគ្រោះ ឬបុគ្គលសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទទៅមជ្ឈមណ្ឌលរបស់រដ្ឋ ឬអង្គការមិនមែនរដ្ឋាភិបាល ដើម្បីទទួលសេវាសង្គមកិច្ចបឋម និងកន្លែងស្នាក់នៅបណ្តោះអាសន្ន ហើយត្រូវប្រគល់**ទម្រង់ទី២៖ទម្រង់បញ្ជូនទៅមជ្ឈមណ្ឌល**(ឧបសម្ព័ន្ធទី១)ទៅមន្ត្រី-បុគ្គលិកមជ្ឈមណ្ឌល។ ក្នុងករណីខេត្ត ដែលគ្មានមជ្ឈមណ្ឌលត្រូវស្នើសុំការអន្តរាគមន៍ពីនាយកដ្ឋានគាំពារជនរងគ្រោះដើម្បីរកកន្លែងស្នាក់នៅបណ្តោះអាសន្ន។

១.៤ មន្ត្រី-បុគ្គលិកមជ្ឈមណ្ឌល ត្រូវទទួល និងយកចិត្តទុកដាក់ថែទាំ ផ្តល់សេវាសុខភាព អនាម័យ សម្លៀកបំពាក់ ចំណីអាហារ[5] និងគ្រប់គ្រងជនរងគ្រោះ ឬបុគ្គលសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ ដោយផ្អែកលើគោលការណ៍ណែនាំ និងបទបញ្ជាផ្ទៃក្នុងរបស់មជ្ឈមណ្ឌល ហើយត្រូវសម្របសម្រួលបញ្ជូនជនរងគ្រោះទៅ មន្ទីរ ស.អ.យ ឬ នាយកដ្ឋានគាំពារជនរងគ្រោះដើម្បីធ្វើសម្ភាសន៍បឋម "ត្រូវមានបន្ទប់សម្ភាសន៍សមស្រប"។

[5] ប្រការ៦នៃប្រកាសលេខ១២៧៤ ស.អ.យ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៤ស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងអំពើអាជីវកម្មផ្លូវភេទដែលស្នាក់ក្នុងមជ្ឈមណ្ឌល។

១.៥ មន្ត្រីទទួលបន្ទុក មន្ទីរ ស.អ.យ ត្រូវធ្វើសម្ភាសន៍បឋមជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ"ជនជាតិខ្មែរ"នៅមន្ទីរ ស.អ.យ រាជធានី ខេត្ត។ មន្ត្រីទទួលបន្ទុកថ្នាក់ជាតិ ត្រូវធ្វើសម្ភាសន៍ជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ "ជនបរទេស" នៅនាយកដ្ឋានគាំពារជនរងគ្រោះ(ទីស្តីការក្រសួង ស.អ.យ)។ ការធ្វើសម្ភាសន៍បឋមត្រូវធ្វើឡើងក្នុងរយៈពេល ២៤ ម៉ោង បន្ទាប់ពីជនរងគ្រោះទទួលឱ្យស្នាក់នៅក្នុងមជ្ឈមណ្ឌល ហើយត្រូវបំពេញ**ទម្រង់ទី៣៖ទម្រង់សម្ភាសន៍បឋម**(ឧបសម្ព័ន្ធទី១)។ ក្នុងករណីជនរងគ្រោះមានបញ្ហាសុខភាព ឬមានការប៉ះទង្គិចផ្លូវចិត្តធ្ងន់ធ្ងរ គឺត្រូវពន្យាពេលធ្វើសម្ភាសន៍បឋម។

១.៦ មន្ត្រីទទួលបន្ទុកមន្ទីរ ស.អ.យ ឬ មន្ត្រីទទួលបន្ទុកថ្នាក់ជាតិ សហការជាមួយ មន្ត្រី-បុគ្គលិកមជ្ឈមណ្ឌល បញ្ជូនបុគ្គលសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ (មានសុខភាពល្អ)ភ្លាមៗតាមដែលអាចធ្វើទៅបាន ឬក្នុងរយៈពេល ៣(បី)ថ្ងៃនៃថ្ងៃធ្វើការទៅមន្ត្រីនគរបាលយុត្តិធម៌ជំនាញដើម្បីកំណត់អត្តសញ្ញាណ ឬអាចធ្វើការសម្ភាសន៍តាមប្រព័ន្ធអនឡាញដើម្បីកំណត់អត្តសញ្ញាណ។

១.៧ មន្ត្រី-បុគ្គលិក មជ្ឈមណ្ឌល"អ្នកប្រឹក្សាផ្លូវចិត្ត" ត្រូវបញ្ជាក់អំពីបញ្ហាសុខភាពផ្លូវចិត្តរបស់បុគ្គលសង្ស័យថារងគ្រោះមុនពេលបញ្ជូនទៅមន្ត្រីនគរបាលយុត្តិធម៌ជំនាញកំណត់អត្តសញ្ញាណ។ ក្នុងករណីបុគ្គលសង្ស័យថារងគ្រោះមានស្ថានភាពប៉ះទង្គិចផ្លូវចិត្តធ្ងន់ធ្ងរត្រូវផ្តល់ព័ត៌មាននេះជូនមន្ត្រីនគរបាលយុត្តិធម៌ជំនាញ ដើម្បីពន្យារពេលការធ្វើសម្ភាសន៍កំណត់អត្តសញ្ញាណ។

១.៨ មន្ត្រីទទួលបន្ទុកមន្ទីរ ស.អ.យ ឬមន្ត្រីទទួលបន្ទុកថ្នាក់ជាតិត្រូវទទួលមកជនរងគ្រោះបន្ទាប់ពីមន្ត្រីនគរបាលយុត្តិធម៌ជំនាញបានកំណត់ថាជាជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ ដោយភ្ជាប់មកជាមួយនូវ **ទម្រង់ទី៤៖កំណត់ហេតុប្រគល់-ទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ** (ឧបសម្ព័ន្ធទី១)។

១.៩ មន្ត្រីទទួលបន្ទុកមន្ទីរ ស.អ.យ ឬមន្ត្រីទទួលបន្ទុកថ្នាក់ជាតិត្រូវជូនព័ត៌មានទៅមន្ត្រីនគរបាលយុត្តិធម៌ជំនាញ ក្នុងករណីរកឃើញថា ជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ ដោយសង្ស័យថាជាជនល្មើស ឬជាប់ពាក់ព័ន្ធជាមួយនឹងជនល្មើស។

**ឧបសម្ព័ន្ធទី១៖**

- ទម្រង់ទី១៖លិខិតបញ្ជូន និងលិខិតធ្វើដំណើរបណ្តោះអាសន្ន
- ទម្រង់ទី២៖ទម្រង់បញ្ជូនទៅមជ្ឈមណ្ឌល
- ទម្រង់ទី៣៖ទម្រង់សម្ភាសន៍បឋម
- ទម្រង់ទី៤៖កំណត់ហេតុប្រគល់-ទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ

មន្ត្រីទទួលបន្ទុកមន្ទីរ ស.អ.យ ឬមន្ត្រីទទួលបន្ទុកថ្នាក់ជាតិ ត្រូវបញ្ចូលទិន្នន័យទម្រង់នៃឧបសម្ព័ន្ធទី១ ដោយអនុវត្តតាមសៀវភៅណែនាំស្តីពីការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ(ឧបសម្ព័ន្ធទី៤)។

**ជំហានទី២៖ការដោះស្រាយករណីជនរងគ្រោះ ឬបុគ្គលសង្ស័យថារងគ្រោះ**

មន្ត្រីទទួលបន្ទុកមន្ទីរ ស.អ.យ មន្ត្រីទទួលបន្ទុកថ្នាក់ជាតិ និងមន្ត្រី-បុគ្គលិក មជ្ឈមណ្ឌល មានភារកិច្ចដោះស្រាយករណីពាក់ព័ន្ធរបស់ជនរងគ្រោះ ឬបុគ្គលសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្សនិងអាជីវកម្មត្រូវអនុវត្តនីតិវិធីដូចខាងក្រោម៖

**<u>នីតិវិធីអនុវត្ត៖</u>**

២.១ មន្ត្រីទទួលបន្ទុកថ្នាក់ជាតិត្រូវបំពេញ**ទម្រង់ទី១៖បែបបទបដិសេធជំនួយដោយស្ម័គ្រចិត្តសម្រាប់ "ជនបរទេស"** (ឧបសម្ព័ន្ធទី២) ដែលរងគ្រោះដោយអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទបដិសេធជំនួយដោយស្ម័គ្រចិត្ត និងអនុញ្ញាតិឱ្យចេញពីមជ្ឈមណ្ឌល ស្របតាមនីតិវិធី។

២.២ មន្ត្រីទទួល បន្ទុកមន្ទីរ ស.អ.យ ត្រូវបំពេញ **ទម្រង់ទី២៖បែបបទបដិសេធជំនួយដោយស្ម័គ្រចិត្តសម្រាប់ "ជនជាតិខ្មែរ"** (ឧបសម្ព័ន្ធទី២) ដែលរងគ្រោះដោយអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទបដិសេធជំនួយដោយស្ម័គ្រចិត្ត និងអនុញ្ញាតិឱ្យចេញពីមជ្ឈមណ្ឌល។

២.៣ មន្ត្រីទទួលបន្ទុក មន្ទីរ ស.អ.យ ត្រូវបញ្ជូនករណីបុគ្គលជា "ជនជាតិខ្មែរ" ដែលជាជនរងគ្រោះមុខសញ្ញាផ្សេងទៅមន្ទីរ ស.អ.យ ជាគោលដៅរបស់ជនរងគ្រោះបន្តនីតិវិធី។ ចំណែកបុគ្គលដែលមិនជាប់ពាក់ព័ន្ធនឹងករណីរងគ្រោះដោយអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទត្រូវបានអនុញ្ញាតិឱ្យចេញពីមជ្ឈមណ្ឌលទៅគ្រួសារនិងសហគមន៍វិញ។

២.៤ អ្នកផ្តល់សេវា ឬអាជ្ញាធរមានសមត្ថកិច្ច ត្រូវរាយការណ៍ជូនមន្ត្រីទទួលបន្ទុកមន្ទីរ ស.អ.យ ឬមន្ត្រីទទួលបន្ទុកថ្នាក់ជាតិ នៅពេលទទួលករណីបុគ្គលសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទដែលបានរត់ចេញពីកន្លែងជួញដូរមនុស្សរបស់ឧក្រិដ្ឋជន។

២.៥ មន្ត្រីទទួលបន្ទុកមន្ទីរ ស.អ.យ ឬមន្ត្រីទទួលបន្ទុកថ្នាក់ជាតិ ត្រូវអនុវត្តជំហានទី១៖ការទទួលជនរគ្រោះ និងសម្របសម្រួលការកំណត់អត្តសញ្ញាណ បន្ទាប់ពីទទួលបានករណី ២.៤។

**ឧបសម្ព័ន្ធទី២៖**

- ទម្រង់ទី១៖បែបបទបដិសេធជំនួយដោយស្ម័គ្រចិត្ត សម្រាប់ "ជនបរទេស"
- ទម្រង់ទី២៖បែបបទបដិសេធជំនួយដោយស្ម័គ្រចិត្ត សម្រាប់ "ជនជាតិខ្មែរ"

មន្ត្រីទទួលបន្ទុក មន្ទីរ ស.អ.យ ឬ មន្ត្រីទទួលបន្ទុក ថ្នាក់ជាតិ ត្រូវបញ្ចូលទិន្នន័យទម្រង់ទី១ និង២ (ឧបសម្ព័ន្ធទី២)ដោយអនុវត្តតាមសៀវភៅណែនាំស្តីពីការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ(ឧបសម្ព័ន្ធទី៤)។

## ៥.២.ការគ្រប់គ្រងករណីជនរងគ្រោះ

ការគ្រប់គ្រងករណី គឺជាវិធីមួយនៃការរៀបចំ និងការអនុវត្តការងារ ដើម្បីដោះស្រាយតម្រូវការរបស់អតិថិជនម្នាក់ៗ (ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ និងគ្រួសារ) នៅក្នុងលក្ខណៈមួយដែលសមស្រប ជាប្រព័ន្ធ និងទាន់ពេលវេលា តាមរយៈការគាំទ្រដោយផ្ទាល់ និង/ឬការបញ្ជូនជនរងគ្រោះទៅ

ទទួលសេវាពីស្ថាប័នឯកទេសរបស់រដ្ឋ ឬអង្គការមិនមែនរដ្ឋាភិបាល។ ជាទូទៅ ការគ្រប់គ្រងករណីអនុវត្តទៅតាមជំហាននីមួយៗដើម្បីកំណត់ និងឆ្លើយតបចំពោះតម្រូវការរបស់ជនរងគ្រោះ។ មន្ត្រីទទួលបន្ទុកថ្នាក់ជាតិ មន្ត្រីទទួលបន្ទុកមន្ទីរ ស.អ.យ មន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តជំហានតាមរូបភាពទី២ខាងក្រោម។

រូបភាពទី២៖ ជំហាននៃការគ្រប់គ្រងករណីជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ




**សំគាល់**-រូបភាពទី២៖ជំហាននៃការគ្រប់គ្រងករណីជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទភ្ជាប់មកពីរូបភាពទី១៖ជំហាននៃការទទួលជនរងគ្រោះ ឬបុគ្គលសង្ស័យថារងគ្រោះផ្តល់សេវាសង្គមកិច្ច។

**ជំហានទី១៖ ទទួលជនរងគ្រោះ និងបើកករណី**

មន្ទីរ ស.អ.យ រាជធានី ខេត្ត ត្រូវបញ្ជូនករណីជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ "ជនជាតិខ្មែរ" ទៅកាន់មន្ទីរ ស.អ.យ រាជធានី ខេត្ត គោលដៅដែលជាលំនៅឋានរបស់គ្រួសារ ឬសាច់ញាតិរបស់ជនរងគ្រោះដើម្បីទទួលចុះឈ្មោះនិងបើកករណី។ នាយកដ្ឋានគាំពារជនរងគ្រោះត្រូវចុះឈ្មោះជនរងគ្រោះ "ជនបរទេស" និងធ្វើមាតុភូមិនិវត្តន៍។ មន្ត្រីទទួលបន្ទុកមន្ទីរ ស.អ.យ មន្ត្រីទទួលបន្ទុកថ្នាក់ជាតិ និងមន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ និងអ្នកពាក់ព័ន្ធត្រូវអនុវត្តនីតិវិធីដូចខាងក្រោម៖

**<u>នីតិវិធីអនុវត្ត៖</u>**

១.១ មន្ត្រីទទួលបន្ទុកមន្ទីរ ស.អ.យ ត្រូវបញ្ជូនព័ត៌មានជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ "ជនជាតិខ្មែរ" និង**ទម្រង់ទី៣៖ ទម្រង់សម្ភាសន៍បឋម** ទៅមន្ទីរ ស.អ.យ រាជធានី ខេត្តគោលដៅ ដែលជាលំនៅឋានរបស់គ្រួសារ ឬសាច់ញាតិជនរងគ្រោះ។ ការផ្តល់ព័ត៌មាន និងឯកសារនេះត្រូវធ្វើឡើងក្នុងរយៈពេល ៧(ប្រាំពី)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីជនរងគ្រោះទទួលយកជំនួយដោយស្ម័គ្រចិត្ត ហើយយល់ព្រមទៅគ្រួសារ និងសហគមន៍វិញ។

១.២ មន្ត្រីទទួលបន្ទុកមន្ទីរ ស.អ.យ ត្រូវធ្វើទំនាក់ទំនងទៅមន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ គោលដៅ នៅក្នុងរយៈពេល ៧(ប្រាំពីរ)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានព័ត៌មាន និងឯកសារ ហើយមន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ ត្រូវសហការជាមួយ អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារ "អ.ក.ន.ក" ឃុំសង្កាត់ដើម្បីស្វែងរកគ្រួសារ និងសាច់ញាតិរបស់ជនរងគ្រោះ។

១.៣ មន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ ត្រូវរាយការណ៍ពីលទ្ធផលនៃការស្វែងរកគ្រួសារ ឬសាច់ញាតិរបស់ជនរងគ្រោះ ដល់មន្ត្រីទទួលបន្ទុក មន្ទីរ ស.អ.យ នៅក្នុងរយៈពេល ៧(ប្រាំពីរ)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបានរកឃើញគ្រួសារ ឬសាច់ញាតិ ហើយត្រូវបញ្ជាក់ឱ្យច្បាស់ពីការឯកភាពរបស់គ្រួសារ ឬសាច់ញាតិយល់ព្រមទទួលយក ឬមិនយល់ព្រមទទួលយកជនរងគ្រោះ។

១.៤ មន្ត្រីទទួលបន្ទុកមន្ទីរ ស.អ.យ ត្រូវរាយការណ៍អំពីលទ្ធផលរកឃើញគ្រួសារ ឬសាច់ញាតិជូននាយកដ្ឋានគាំពារជនរងគ្រោះ នៅក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ ដើម្បីសម្របសម្រួលជាមួយមន្ទីរ ស.អ.យ និងមជ្ឈមណ្ឌល ដើម្បីរៀបចំផែនការបញ្ជូនជនរងគ្រោះ (ក្នុងករណីគ្រួសារ ឬសាច់ញាតិយល់ព្រមទទួល)។

១.៥ មន្ត្រីទទួលបន្ទុកមន្ទីរ ស.អ.យ សហការជាមួយមន្ត្រី-បុគ្គលិកមជ្ឈមណ្ឌល ក្រោមការសម្របសម្រួលពីមន្ត្រីទទួលបន្ទុកថ្នាក់ជាតិ ត្រូវបញ្ជូនជនរងគ្រោះទៅមន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ គោលដៅនៅក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ។ ក្នុងករណីគ្រួសារ ឬសាច់ញាតិមិនយល់ព្រមទទួល ឬសាមីខ្លួនបដិសេធមិនព្រមទៅរស់នៅជាមួយគ្រួសារ ឬសាច់ញាតិវិញគឺត្រូវគោរពសិទ្ធិសម្រេចរបស់ជនរងគ្រោះ។

១.៦ មន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ សហការជាមួយ អ.ក.ន.ក បញ្ជូនជនរងគ្រោះទៅកាន់គ្រួសារ ឬសាច់ញាតិ និងរាយការណ៍ជូនមន្ត្រីទទួលបន្ទុកមន្ទីរ ស.អ.យ ដើម្បីស្នើសុំបើកករណី។ មន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ "អ្នកកាន់ករណី" ត្រូវបំពេញ**ទម្រង់ទី១៖ទម្រង់ទទួលជនរងគ្រោះនិងស្វែងរកគ្រួសារ**(ឧបសម្ព័ន្ធទី៣)។

១.៧ មន្ត្រីទទួលបន្ទុកថ្នាក់ជាតិ ត្រូវទទួលចុះឈ្មោះជនរងគ្រោះជា "ជនបរទេស" ដើម្បីបើកករណីនៅក្នុងរយៈពេល ៧(ប្រាំពីរ)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីមន្ត្រីនគរបាលយុត្តិធម៌បានកំណត់ថា ជាជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ។ មន្ត្រីទទួលបន្ទុកថ្នាក់ជាតិមិនចាំធ្វើការបំពេញទម្រង់ទី១៖ទម្រង់ទទួលជនរងគ្រោះនិងស្វែងរកគ្រួសារ(ឧបសម្ព័ន្ធទី៣)ទេ។

**ឧបសម្ព័ន្ធទី៣៖**

-ទម្រង់ទី១៖ទម្រង់ទទួលជនរងគ្រោះនិងស្វែងរកគ្រួសារ

មន្ត្រីទទួលបន្ទុកមន្ទីរ ស.អ.យ ឬ មន្ត្រីទទួលបន្ទុកថ្នាក់ជាតិ ត្រូវបញ្ចូលទិន្នន័យទម្រង់ទី១៖ទម្រង់ទទួលជនរងគ្រោះនិងស្វែងរកគ្រួសារ (ឧបសម្ព័ន្ធទី៣) ដោយអនុវត្តតាមសៀវភៅណែនាំស្តីពីការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ(ឧបសម្ព័ន្ធទី៤)។

**ជំហានទី២៖ការប៉ាន់ប្រមាណគ្រប់ជ្រុងជ្រោយ**

ការប៉ាន់ប្រមាណគ្រប់ជ្រុងជ្រោយកើតឡើងបន្ទាប់ពីការប៉ាន់ប្រមាណបឋម(ទម្រង់ទី៣៖ទម្រង់សម្ភាសន៍បឋម) និងផ្តល់ការយល់ដឹងស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយអំពីស្ថានភាពរបស់ជនរងគ្រោះ។ ការប៉ាន់ប្រមាណគ្រប់ជ្រុងជ្រោយពិនិត្យមើលលើពីតម្រូវការមូលដ្ឋាននិងតម្រូវការបន្ទាន់របស់ជនរងគ្រោះ។ កត្តានានាដែលត្រូវពិចារណានៅក្នុងអំឡុងពេលនៃការប៉ាន់ប្រមាណគ្រប់ជ្រុងជ្រោយ អាចអាស្រ័យលើវិសាលភាពនៃសេវាដែលស្ថាប័ន/អង្គភាពរបស់អ្នកកាន់ករណី។ ការប៉ាន់ប្រមាណគ្រប់ជ្រុងជ្រោយមិនគួរពិចារណាតែលើហានិភ័យ និងកត្តាគ្រោះថ្នាក់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងកំណត់កត្តាវិជ្ជមាន និងការកត្តាការពារ ព្រមទាំងភាពខ្លាំងរបស់ជនរងគ្រោះផងដែរ។ មន្ត្រីទទួលបន្ទុកមន្ទីរ ស.អ.យ មន្ត្រីទទួលបន្ទុកថ្នាក់ជាតិ និងមន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ និងអ្នកពាក់ព័ន្ធត្រូវអនុវត្តនីតិវិធីដូចខាងក្រោម៖

**នីតិវិធីអនុវត្ត៖**

២.១ មន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ "**អ្នកកាន់ករណី**" ត្រូវចាប់ផ្តើមធ្វើការប៉ាន់ប្រមាណគ្រប់ជ្រុងជ្រោយដោយមានជំនួយពី គ.ក.ន.ក ឃុំសង្កាត់ ប្រមូលព័ត៌មានឱ្យកាន់តែច្បាស់លាស់ច្រើនទៀតអំពីទិន្នន័យជនរងគ្រោះ និងគ្រួសារ ឬសាច់ញាតិ បន្ទាប់ពីទុកដាក់រងគ្រោះឱ្យរស់នៅជាមួយគ្រួសារ ឬសាច់ញាតិ។

២.២ អ្នកកាន់ករណី ត្រូវធ្វើការប៉ាន់ប្រមាណគ្រប់ជ្រុងជ្រោយដោយចាប់ផ្តើមភ្លាមៗយោងទៅលើស្ថានភាពអំពីសុវត្ថិភាព និងតម្រូវការចាំបាច់របស់ជនរងគ្រោះ។ ការប៉ាន់ប្រមាណគ្រប់ជ្រុងជ្រោយត្រូវតែបញ្ចប់នៅក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការ។ គោលបំណងនៃការប៉ាន់ប្រមាណគ្រប់ជ្រុងជ្រោយគឺដើម្បីកំណត់ថា៖

- តើជនរងគ្រោះអាចនឹងបន្តរងគ្រោះថ្នាក់ធ្ងន់ធ្ងរ ឬប្រឈមនឹងវិបត្តិផ្លូវចិត្តធ្ងន់ធ្ងរ និងការរើសអើង និងមាក់ងាយពីសមាជិកគ្រួសារ និងសហគមន៍ដែរឬទេ?
- តើគ្រួសារ ឬសាច់ញាតិអាចមើលថែទាំជនរងគ្រោះ និងឆ្លើយតបបានសមស្របទៅនឹងតម្រូវការរបស់ជនរងគ្រោះដែរឬទេ?

អ្នកកាន់ករណីត្រូវបំពេញ **ទម្រង់ទី២៖ទម្រង់ប៉ាន់ប្រមាណគ្រួសារ** (ឧបសម្ព័ន្ធទី៣)។

២.៣ អ្នកកាន់ករណីត្រូវពិនិត្យលទ្ធផលនៃរបាយការណ៍ប៉ាន់ប្រមាណគ្រប់ជ្រុងជ្រោយដើម្បីធ្វើការសម្រេចចិត្តថាជនរងគ្រោះមានសុវត្ថិភាព គ្មានការរើសអើស មាក់ងាយនិងមានសេវាសមស្របចាំបាច់គ្រប់គ្រាន់សម្រាប់រៀបចំផែនការករណី ឬត្រូវរៀបចំសន្និសិទករណីសហគមន៍បន្ថែមទៀតដើម្បីដោះស្រាយបញ្ហារបស់ជនរងគ្រោះ និងគ្រួសារ ឬសាច់ញាតិ។

២.៤ មន្ត្រីទទួលបន្ទុក ថ្នាក់ជាតិ ត្រូវរៀបចំលិខិតផ្លូវការ ជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាផ្ញើទៅក្រសួង ស្ថានប័នពាក់ព័ន្ធ និងស្ថានតំណាងប្រចាំនៅកម្ពុជាដើម្បីធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះ នៅក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីមន្ត្រីនគរបាលយុត្តិធម៌ជំនាញកំណត់អត្តសញ្ញាណថា "ជនបរទេស" ជាជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ និងមិនតម្រូវឱ្យបំពេញទម្រង់ទី២(ឧបសម្ព័ន្ធទី៣)ទេ។

ឧបសម្ព័ន្ធទី៣៖
-ទម្រងទី២៖ទម្រង់ប៉ាន់ប្រមាណគ្រួសារ

មន្ត្រីទទួលបន្ទុកមន្ទីរ ស.អ.យ ឬមន្ត្រីទទួលបន្ទុកថ្នាក់ជាតិ ត្រូវបញ្ចូលទិន្នន័យទម្រង់ទី២៖ទម្រង់ប៉ាន់ប្រមាណគ្រួសារ(ឧបសម្ព័ន្ធទី៣)ដោយអនុវត្តតាមសៀវភៅណែនាំស្តីពីការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ(ឧបសម្ព័ន្ធទី៤)។

***ការប្រុងប្រយ័ត្ន***

- *សូមប្រុងប្រយ័ត្ននិងយកចិត្តទុកដាក់ចំពោះសំណួរដែលត្រូវសួរអតិថិជន ជៀសវាងសួរចម្លើយអតិថិជន។*
- *សូមកុំបង្ហាញនូវការបង្អាប់បញ្ហា។ ប្រសិនបើអតិថិជននិយាយសារចុះសារឡើងពីប្រធានបទមួយទៅប្រធានបទមួយទៀតវាជារឿងធម្មតាទេ។ អ្នកកាន់ករណីមិនចាំបាច់ត្រូវអនុវត្តតាមលំដាប់លំដោយនៅក្នុងទម្រង់ប៉ាន់ប្រមាណឡើយ។*
- *សូមប្រើប្រាស់ជំនាញគាំទ្រផ្លូវចិត្ត និងចិត្តសង្គម និងបច្ចេកទេសទំនាក់ទំនង(ទំនាក់ទំនងដោយបង្ហាញតាមពាក្យសម្តី ការនិយាយប្រកបដោយប្រសិទ្ធភាព និងការស្តាប់សកម្ម) និងកែសម្រួលជំនាញ និងបច្ចេកទេសទាំងនេះទៅតាមអាយុ ដំណាក់កាលនៃការអភិវឌ្ឍ និងសមត្ថភាពរបស់អតិថិជន។*

## ការរៀបចំសន្និសីទករណីសហគមន៍

ក្នុងករណីមន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ សម្រេចចិត្តរៀបចំសន្និសិទករណីសហគមន៍ គឺគាត់ត្រូវស្នើសុំទៅមន្ត្រីទទួលបន្ទុក មន្ទីរ ស.អ.យ ឱ្យជួយគាំទ្របច្ចេកទេសរៀបចំសន្និសីទករណី

សហគមន៍។ ការរៀបចំសន្និសីទករណីសហគមន៍មានគោលបំណងដើម្បីស្វែងរកសេវាគាំទ្រដល់ជនរងគ្រោះ និងគ្រួសារ ឬសាច់ញាតិ។ មន្ត្រីទទួលបន្ទុកមន្ទីរ ស.អ.យ មន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ និងអ្នកពាក់ព័ន្ធត្រូវអនុវត្តនីតិវិធីដូចខាងក្រោម៖

**<u>នីតិវិធីអនុវត្ត៖</u>**

២.៥ មន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំសន្និសីទករណីសហគមន៍ ក្នុងរយៈពេល ១០(ដប់)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ទទួលបានការឯកភាពពីមន្ត្រីទទួលបន្ទុកមន្ទីរ ស.អ.យ "អ្នកត្រួតពិនិត្យករណី"។

២.៦ មន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ ត្រូវអញ្ជើញអ្នកពាក់ព័ន្ធដើម្បីចូលរួមសន្និសីទករណីសហគមន៍ ដែលអាចរួមមាន៖

(ក) ជនរងគ្រោះ និងគ្រួសារ ឬសាច់ញាតិ

(ខ) អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារ "អ.ក.ន.ក"

(គ) មន្ត្រីទទួលបន្ទុក មន្ទីរ ស.អ.យ រាជធានី ខេត្ត

(ឃ)មន្ត្រីសាខា មជជ និងមជព រាជធានី ខេត្ត

(ង)មន្ត្រីអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ

(ច)មន្ត្រីនគរបាល ប៉ុស្តិ៍រដ្ឋបាល ឃុំ សង្កាត់

(ឆ)អ្នកផ្សេងទៀតដែលគិតថាពាក់ព័ន្ធ។

## ក ការចូលរួមសន្និសីទករណីសហគមន៍

២.៧ មន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ ជូនដំណឹងដល់អ្នកពាក់ព័ន្ធទាំងអស់អំពីកាលបរិច្ឆេទ និងទីកន្លែងរៀបចំសន្និសីទករណីសហគមន៍យ៉ាងហោចណាស់ក្នុងរយៈពេល ៧(ប្រាំពីរ)ថ្ងៃនៃថ្ងៃធ្វើការ មុនពេលកាលបរិច្ឆេទនៃសន្និសីទករណីសហគមន៍និងត្រូវបញ្ជាក់ថាវត្តមានផងដែរ។

២.៨ អ្នកចូលរួមគួរមានចំនួនពី ១២-១៥នាក់ ប្រសិនបើសន្និសិទករណីសហគមន៍មានអ្នកចូលច្រើន និងបាកសម្រាប់សមាជិកគ្រប់គ្នាបញ្ចេញមតិ និងយល់ព្រមលើផែនការករណី។

## ខ ប្រធានសន្និសីទករណីសហគមន៍

២.៩ មន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ ត្រូវពិភាក្សាជាមួយ អ.ក.ន.ក ដើម្បីកំណត់បុគ្គលណាម្នាក់ដែលសក្តិសមធ្វើជាប្រធានសន្និសីទករណី។

- បើអាចជ្រើសរើសបាន ប្រធានសន្និសីទករណីសហគមន៍ (ជាមេឃុំ ឬអ្នកមានចំណេះដឹងខ្លះៗអំពីកិច្ចគាំពារជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ)។
- ប្រធានសន្និសីទករណីត្រូវមានតួនាទី៖
  - ធានាថា អ្នកចូលរួមសន្និសីទករណីទាំងអស់យល់ពីគោលបំណងនៃសន្និសីទករណី
  - ជូនដំណឹងដល់អ្នកចូលរួមអំពី នីតិវិធីនៃសន្និសីទករណី
  - រំលឹកដល់អ្នកចូលរួមទាំងអស់ថា សន្និសីទករណីគឺជាការសម្ងាត់

- ○ បង្គលក្ខណៈឱ្យអ្នកចូលរួមមានសិទ្ធិពេញលេញក្នុងការពិភាក្សា និងធ្វើការសម្រេចចិត្ត
- ○ ធានាថាសន្និសីទករណី គិតពិចារណាលើព័ត៌មានទាំងអស់ និងទស្សនៈរបស់អ្នកចូលរួម និងគោរពតាមបំណងប្រាថ្នា និងទស្សនៈរបស់ជនរងគ្រោះ។

## គ នីតិវិធីសន្និសីទករណី

២.១០ មុនពេលចាប់ផ្តើមសន្និសីទករណី ប្រធានត្រូវជម្រាបជូនសមាជិកថា អាចនឹងមានការស្នើឱ្យសមាជិកក្រុមគ្រួសារ ឬសាច់ញាតិ និងជនរងគ្រោះ ចាកចេញពីសន្និសីទករណីមួយរយៈពេលខ្លីនៅពេលដែលមានការពិភាក្សាគ្នារវាងអ្នកចូលរួមដែលមិនមែនជាសមាជិកគ្រួសារឬសាច់ញាតិរបស់ជនរងគ្រោះ។

២.១១ មន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ ត្រូវទទួលខុសត្រូវធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃសន្និសីទករណី ដែលនឹងរួមបញ្ចូលនូវអនុសាសន៍ ឬកិច្ចព្រមព្រៀងដែលបានឈានទៅដល់ការឯកភាព នៅក្នុងសន្និសីទករណីសហគមន៍។

២.១២ រាល់ឯកសារនិងកំណត់ហេតុនៃសន្និសីទករណីត្រូវទុកជាការសម្ងាត់ ហើយមិនត្រូវបញ្ចេញឱ្យនរណាម្នាក់ក្រៅពីសមាជិកនៃសន្និសីទករណីឡើយ ប៉ុន្តែអាចផ្តល់ជូនបានប្រសិនបើមានការស្នើសុំជាពិសេសណាមួយ ។

## ឃ អនុសាសន៍នៃសន្និសីទករណីសហគមន៍

២.១៣ នៅចុងបញ្ចប់នៃសន្និសីទករណីសហគមន៍ សមាជិកដែលមិនមែនជាគ្រួសារ ឬសាច់ញាតិរួមជាមួយនឹងប្រធានត្រូវពិចារណាលើការប៉ាន់ប្រមាណគ្រប់ជ្រុងជ្រោយ និងព័ត៌មានផ្សេងទៀតដើម្បីសម្រេចថា តើជនរងគ្រោះមានសេវាគាំទ្រ ឬមានបញ្ហាបន្តទៀតដែរឬទេ ?

២.១៤ នៅពេលដែលសមាជិកដែលមិនមែនជាក្រុមគ្រួសារ ឬសាច់ញាតិសម្រេចថាមិនមានភស្តុតាងដែលបញ្ជាក់ថា ជនរងគ្រោះមិនមានបញ្ហាបន្តទៀត សន្និសីទករណីនេះអាចៈ

(ក)មិនត្រូវចាត់វិធានការបន្ថែមទៀតឡើយ

(ខ)ត្រូវបញ្ជូនករណីជនរងគ្រោះ និងគ្រួសារទៅ គ.ក.ន.ក ដើម្បីទទួលសេវាគាំទ្រ។

២.១៥ នៅពេលដែលសន្និសីទករណីសន្និដ្ឋានថា ជនរងគ្រោះទំនងជារងគ្រោះថ្នាក់ ទោះបីជាមានផែនការករណីក៏ដោយ ក្នុងករណីនេះ ប្រធានសន្និសីទករណីត្រូវបញ្ជូនករណីត្រលប់ទៅមន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ ភ្លាមដើម្បីចាត់វិធានការបន្ទាន់។

២.១៦ នៅពេលដែលមន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ ទទួលបានអនុសាសន៍ពីសន្និសីទករណី គាត់ត្រូវពិគ្រោះយោបល់ជាមួយមន្ត្រីទទួលបន្ទុក មន្ទីរ ស.អ.យ ដើម្បីធានាថា អនុសាសន៍ទាំងនេះ គឺគ្រប់គ្រាន់ដើម្បីការពារសុវត្ថិភាពជនរងគ្រោះ។

២.១៧ មន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ មានអំណាចក្នុងការបដិសេធចំពោះអនុសាសន៍របស់សន្និសីទករណីសហគមន៍បាន ប្រសិនបើអនុសាសន៍នោះមិនសមស្រប និងទំនងជាធ្វើឱ្យជនរងគ្រោះបន្តគ្រោះម្តងទៀត។

***ត្រូវយល់ដឹង៖***
*ទោះបីជាការប៉ាន់ប្រមាណគ្រប់ជ្រុងជ្រោយអាចត្រូវបានបញ្ចប់ក្តី ការប៉ាន់ប្រមាណមិនមែនជាដំណើរការតែ ម្តង ទៀយ ប៉ុន្តែជាដំណើរការជាបន្តបន្ទាប់៖ ស្ថានភាព ឬកាលៈទេសៈនានាអាចប្រែប្រួល និងអាចតម្រូវឱ្យមានការធ្វើបច្ចុប្បន្នភាពចំពោះរបាយការណ៍ប៉ាន់ប្រមាណ ឬការផ្លាស់ប្តូរសេវា ឬការគាំទ្រណាមួយដែលត្រូវបានផ្តល់ជូនជនរងគ្រោះ និងគ្រួសារ ឬសាច់ញាតិ។*

**ជំហានទី៣៖រៀបចំផែនការសម្រាប់ករណី**

ការរៀបចំផែនការករណីគប្បី SMART=Specific ជាក់លាក់; Measurable អាចវាស់វែងបាន Achievable អាចសម្រេចបាន Realistic or Relevant ប្រាកដប្រជាឬពាក់ព័ន្ធ; Time-bound មានពេលវេលាកំណត់។ អ្នកកាន់ករណី "មន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ" អាចប្រើប្រាស់បាន តាមគំរូនៃការដោះស្រាយបញ្ហានេះថា SNAP=State the problem បង្ហាញអំពីបញ្ហា; Name of goal កំណត់គោលបំណង; All possible actions សកម្មភាព/វិធានការដោះស្រាយទាំងអស់ដែលអាចមាន; Pick the best action and try it out ជ្រើសរើសសកម្មភាព/វិធានការដែលល្អបំផុត និងសាកល្បងអនុវត្តវា ដើម្បីដោះស្រាយបញ្ហាមួយ តាមរយៈការកំណត់សកម្មភាព/វិធានការដែលអាចអនុវត្តបានចំពោះបញ្ហាមួយ និងជ្រើសរើសសកម្មភាព/វិធានការដែលល្អបំផុតសម្រាប់ផែនការករណី។ មន្ត្រីទទួលបន្ទុកមន្ទីរ ស.អ.យ មន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ និងអ្នកពាក់ព័ន្ធត្រូវអនុវត្តនីតិវិធីដូចខាងក្រោម៖

**<u>នីតិវិធីអនុវត្ត៖</u>**

៣.១ មន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ ត្រូវពិនិត្យរបាយការណ៍ប៉ាន់ប្រមាណគ្រួសារឬរបាយការណ៍សន្និសីទករណីសហគមន៍ដើម្បីរៀបចំផែនការករណី ហើយត្រូវបំពេញ **ទម្រង់ទី៣៖ទម្រង់ផែនការករណី**(ឧបសម្ព័ន្ធទី៣)។ ការរៀបចំផែនការករណីត្រូវកំណត់រយៈពេលអនុវត្ត ១(មួយ)ឆ្នាំម្តង។

៣.២ មន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ចំណុចដៅនៃសូចនាករលទ្ធផលរំពឹងទុក និងអ្នកទទួលបន្ទុកអនុវត្តសូចនាករ នៅក្នុងផែនការករណីដើម្បីឆ្លើយតបតម្រូវការរបស់ជនរងគ្រោះនិងគ្រួសារ ឬសាច់ញាតិ។

៣.៣ មន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ ត្រូវសម្របសម្រួល និងលើកទឹកចិត្តដល់រដ្ឋបាលឃុំ សង្កាត់ អង្គការមិនមែនរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធ អនុវត្តសកម្មភាពដែលបានឯកភាពនៅក្នុងផែនការករណីឱ្យទទួលបានជោគជ័យ។

៣.៤ មន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ពេលវេលាតាមដានការអនុវត្តផែនការករណី និងស្នើសុំការគាំទ្របច្ចេកទេសពីមន្ទីរ ស.អ.យ រាជធានី ខេត្ត។

៣.៥ មន្ត្រីទទួលបន្ទុកថ្នាក់ជាតិ សហការជាមួយមន្ត្រី-បុគ្គលិករបស់មជ្ឈមណ្ឌលដើម្បីរៀបចំផែនការមាតុភូមិនិវត្តន៍ជនរងគ្រោះជា "ជនបរទេស" បន្ទាប់ពីស្ថាប័នពាក់ព័ន្ធនានា និងស្ថានតំណាងបរទេសប្រចាំប្រទេសកម្ពុជា ឯកភាពជាផ្លូវការ។

៣.៦ មន្ត្រីទទួលបន្ទុកមន្ទីរ ស.អ.យ សហការជាមួយមន្ត្រី-បុគ្គលិកមជ្ឈមណ្ឌលត្រូវរៀបចំឯកសារឱ្យចេញពីមជ្ឈមណ្ឌល ចំពោះជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទជា "ជនជាតិខ្មែរ" ដែលបដិសេធមិនទទួលយកសេវាសង្គមកិច្ច និងសេវាពាក់ព័ន្ធ។

ឧបសម្ព័ន្ធទី៣៖

-ទម្រងទី៣៖ទម្រង់ផែនការករណី

មន្ត្រីទទួលបន្ទុកមន្ទីរ ស.អ.យ ឬមន្ត្រីទទួលបន្ទុកថ្នាក់ជាតិត្រូវបញ្ចូលទិន្នន័យទម្រង់ទី៣៖ទម្រង់ផែនការករណី( ឧបសម្ព័ន្ធទី៣ )ដោយអនុវត្តតាមសៀវភៅណែនាំស្តីពីការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ( ឧបសម្ព័ន្ធទី៤ )។

**ជំហានទី៤៖ការអនុវត្តផែនការសម្រាប់ករណី**

នៅពេលរៀបចំផែនការករណីហើយ ត្រូវបន្តទៅជំហានបន្ទាប់ នោះគឺការអនុវត្តផែនការ។ ដោយផ្អែកលើផែនការនេះ អ្នកកាន់ករណីគប្បីត្រូវធ្វើការងារជាមួយជនរងគ្រោះ និងគ្រួសារ ឬសាច់ញាតិ និងសហគមន៍ ព្រមទាំងអ្នកផ្តល់សេវា ដើម្បីធានាថា ជនរងគ្រោះទទួលបានសេវាសមស្រប។ មន្ត្រីទទួលបន្ទុកមន្ទីរ ស.អ.យ មន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ និងអ្នកពាក់ព័ន្ធត្រូវអនុវត្តនីតិវិធីដូចខាងក្រោម៖

**<u>នីតិវិធីអនុវត្ត៖</u>**

៤.១ មន្ត្រីទទួលបន្ទុកមន្ទីរ ស.អ.យ ត្រូវបំពេញ**ទម្រង់ទី៤-ទម្រង់សមាហរណកម្ម**( ឧបសម្ព័ន្ធទី៣ ) ដើម្បីអនុញ្ញាតិឱ្យជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទជា "ជនជាតិខ្មែរ" ដែលបដិសេធមិនទទួលយកសេវាសង្គមកិច្ច និងសេវាពាក់ព័ន្ធ នៅក្នុងរយៈពេល១៥( ដប់ ) ថ្ងៃនៃថ្ងៃធ្វើការ។

៤.២ មន្ត្រីទទួលបន្ទុក មន្ទីរ ស.អ.យ សហការជាមួយ មន្ត្រី-បុគ្គលិកមជ្ឈមណ្ឌល ក្រោមការសម្របសម្រួលពីមន្ត្រីទទួលបន្ទុកថ្នាក់ជាតិ ត្រូវបញ្ជូនជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទដែលបដិសេធមិនទទួលយកសេវានៅសហគមន៍ ប៉ុន្តែគាត់ស្ម័គ្រទទួលយកការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ។ ការបញ្ជូនជនរងគ្រោះទៅទទួលការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនៅក្នុងរយៈពេល ១៥( ដប់ប្រាំ )ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានការឯកភាពជាផ្លូវការពីភាគីសាលាបណ្តុះបណ្តាល។

៤.៣ មន្ត្រីទទួលបន្ទុកមន្ទីរ ស.អ.យ មានភារកិច្ចទទួលខុសត្រូវគ្រប់គ្រងករណីជនរងគ្រោះដែលស្ម័គ្រចិត្តទទួលសេវាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ។ មន្ត្រីទទួលបន្ទុកមន្ទីរ ស.អ.យ មិនត្រូវសម្រេចចិត្តបន្ត ឬបិទករណីទេ គឺត្រូវគោរពសិទ្ធិជនរងគ្រោះក្នុងការសម្រេចចិត្ត។

៤.៤ មន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ ជា "អ្នកកាន់ករណី" ត្រូវធ្វើការសម្របសម្រួលការអនុវត្តផែនការករណី និងតាមដានការអនុវត្តផែនការករណី។

៤.៥ មន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ រៀបចំប្រជុំពិនិត្យការអនុវត្តផែនការករណីជាមួយភាគីពាក់ព័ន្ធផ្តល់សេវាទាំងអស់នៅខែទី៦ នៃការអនុវត្តផែនការ និងនៅខែទី១១ នៃការអនុវត្តផែនការណីប្រចាំឆ្នាំ ( ក្នុងករណីចាំបាច់កិច្ចប្រជុំអាចរៀបចំពេលណាក៏បាន )។

៤.៦ មន្ត្រីទទួលបន្ទុកថ្នាក់ជាតិ ត្រូវសម្របសម្រួលជាស្ថាប័នពាក់ព័ន្ធ អង្គការដៃគូ និងស្ថានតំណាងប្រទេសប្រចាំកម្ពុជាធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះជា "ជនបរទេស"ទៅកាន់ប្រទេសកំណើតវិញ ត្រូវបំពេញ ទម្រង់ទី៤ក-ទម្រង់មាតុភូមិនិវត្តន៍ (ឧបសម្ព័ន្ធទី៣)។

ឧបសម្ព័ន្ធទី៣៖

-ទម្រងទី៤៖ទម្រង់សមាហរណកម្ម

-ទម្រងទី៤ក៖ទម្រង់មាតុភូមិនិវត្តន៍

មន្ត្រីទទួលបន្ទុកមន្ទីរ ស.អ.យ ឬមន្ត្រីទទួលបន្ទុកថ្នាក់ជាតិ ត្រូវបញ្ចូលទិន្នន័យទម្រង់ទី៤៖ទម្រង់សមាហកម្មនិងទម្រង់ទី៤ក៖ទម្រង់មាតុភូមិនិវត្តន៍ ដោយអនុវត្តតាមសៀវភៅណែនាំស្តីពីការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ(ឧបសម្ព័ន្ធទី៤)។

**ជំហានទី៥៖ការតាមដាន និងពិនិត្យឡើងវិញ**

បើទោះជាការតាមដានករណី និងការពិនិត្យឡើងវិញនៅជំហានជាមួយគ្នាក្តី ការតាមដានករណី និងការពិនិត្យឡើងវិញមានគោលដៅខុសគ្នា ប៉ុន្តែមានគោលបំណងដូចគ្នានោះគឺដើម្បីធានានូវការអនុវត្តផែនការករណី ហើយផែនការករណីបន្តមានភាពពាក់ព័ន្ធ និងបំពេញតម្រូវការរបស់ជនរងគ្រោះ។

- **ការតាមដាន** ពាក់ព័ន្ធនឹងការពិនិត្យមើលថាជនរងគ្រោះ និងគ្រួសារ ឬសាច់ញាតិកំពុងទទួលបានសេវានិងការគាំទ្រសមស្រប ដើម្បីបំពេញតម្រូវការរបស់ពួកគេ ដូចការកំណត់នៅក្នុងផែនការករណី ការតាមដានសុវត្ថិភាព និងសុខុមាលភាពរបស់ជនរងគ្រោះ ការពិនិត្យថាស្ថានភាពរបស់ពួកគេមានស្ថិរភាព និងមានវឌ្ឍនភាពវិជ្ជមានស្របទៅតាមផែនការករណី ការវាយតម្លៃថាតើចាំបាច់ត្រូវមានការផ្លាស់ប្តូរដៃរឬទេ ព្រមទាំងរក្សា និងពង្រឹងទំនាក់ទំនង។ ការតាមដានត្រូវបានអនុវត្តជាទៀងទាត់នៅក្នុងអំឡុងពេលនៃដំណើរការគ្រប់គ្រងករណី ជាមួយនឹងជនរងគ្រោះ និងតួអង្គផ្សេងទៀត ដើម្បីពិនិត្យថា សកម្មភាពជាក់លាក់ត្រូវបានអនុវត្ត ហើយសេវាត្រូវបានផ្តល់។
- **ការពិនិត្យឡើងវិញ** លើផែនការករណីអនុញ្ញាតឱ្យអ្នកដោះស្រាយស្ថានភាព និងកាលៈទេសៈដែលកំពុងផ្លាស់ប្តូរ និងធានាថា ផែនការនេះបន្តមានភាពពាក់ព័ន្ធនិងបំពេញតម្រូវការរបស់ជនរងគ្រោះ។ ការពិនិត្យឡើងវិញគប្បីកើតឡើងយ៉ាងហោចណាស់ជារៀងរាល់បីខែម្តង ឬតាមលទ្ធភាពជាក់ស្តែង។ ក្នុងករណីស្មុគស្មាញ ដូចជាករណីទាំងឡាយដែលត្រូវបានគ្រប់គ្រងក្នុងរយៈពេលយ៉ាងយូរ ឬពាក់ព័ន្ធនឹងតួអង្គជាច្រើន អាចត្រូវការ ការពិនិត្យឡើងវិញជាលក្ខណៈពហុវិស័យ/អន្តរស្ថាប័ន ឬទីភ្នាក់ងារ (បើសមស្រប) ដែលគេហៅថា "សន្និសីទករណី" ដូចបង្ហាញខាងលើ។

ដើម្បីអនុវត្តការតាមដាននិងពិនិត្យឡើងវិញ មន្ត្រីទទួលបន្ទុកមន្ទីរ ស.អ.យ មន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ និងអ្នកពាក់ព័ន្ធត្រូវអនុវត្តនីតិវិធីដូចខាងក្រោម៖

**<u>នីតិវិធីអនុវត្ត៖</u>**

៥.១ មន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ ផ្តល់សិទ្ធិឱ្យ អ.ក.ន.ក ចុះតាមដានជនរងគ្រោះក្នុងរយៈពេល ១៥(ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីចាប់ផ្តើមអនុវត្តផែនការករណី និងបន្តអនុវត្ត ១(មួយ)ខែម្តង ឬតាមលទ្ធភាពជាក់ស្តែង។

៥.២ មន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ "អ្នកកាន់ករណី" ចុះតាមជនការអនុវត្តផែនការករណីក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីការចាប់ផ្តើមអនុវត្តផែនការករណី និងបន្តអនុវត្ត ២(ពីរ)ខែម្តង ឬតាមលទ្ធភាពជាក់ស្តែង។

៥.៣ មន្ត្រីទទួលបន្ទុកមន្ទីរ ស.អ.យ "អ្នកត្រួតពិនិត្យករណី" ចុះតាមដានការអនុវត្តផែនការករណីក្នុងរយៈពេល ៩០(កៅសិប)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីការចាប់ផ្តើមអនុវត្តផែនការករណី និងបន្តអនុវត្ត ៣(បី)ខែម្តង ឬតាមលទ្ធភាពជាក់ស្តែង។

៥.៤ មន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ "អ្នកកាន់ករណី" មន្ត្រីទទួលបន្ទុកមន្ទីរ ស.អ.យ "អ្នកត្រួតពិនិត្យករណី" និងអ្នកពាក់ព័ន្ធ ត្រូវចុះតាមដាននិងពិនិត្យឡើងវិញរួមគ្នាលើកទី១ នៅក្នុងរយៈពេល៦(ប្រាំមួយ)ខែបន្ទាប់ពីកាចាប់ផ្តើមអនុវត្តផែនការករណី។ ក្នុងករណីការអនុវត្តផែនការករណីសម្រេចលទ្ធផលក្រោម ៥០% ឬមានបញ្ហាស្មុគ្រស្មាញ គឺត្រូវសម្រេចចិត្តរៀបចំ **កិច្ចប្រជុំគ្រប់គ្រងករណី**។

៥.៥ ការចុះតាមដាននិងពិនិត្យឡើងវិញរួមគ្នាលើកទី២ គឺនៅរយៈពេល ១(មួយ)ខែមុននៃការបញ្ចប់ការអនុវត្តផែនការករណីប្រចាំឆ្នាំដើម្បីធ្វើការសម្រេចថា"តើត្រូវបិទករណី ឬបន្តអនុវត្តផែនការករណី ឬកែសម្រួលផែនការករណីឡើងវិញ"។

៥.៦ មន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ "អ្នកកាន់ករណី" មន្ត្រីទទួលបន្ទុកមន្ទីរ ស.អ.យ "អ្នកត្រួតពិនិត្យករណី"ត្រូវបំពេញ**ទម្រង់ទី៥ៈទម្រង់តាមដាន**(ឧបសម្ព័ន្ធទី៣) នៅរាល់ពេលចុះតាមដាន និងត្រួតពិនិត្យឡើងវិញ។

**ការផ្ទេរករណីជនរងគ្រោះ**

៥.៧ ក្នុងករណីជនរងគ្រោះផ្លាស់ប្តូរទីលំនៅឋានផ្សេង ប៉ុន្តែនៅក្នុងភូមិសាស្ត្ររាជធានីខេត្តតែមួយ មន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ "អ្នកកាន់ករណី"ចាស់ត្រូវផ្ទេរករណីនេះទៅកាន់មន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ "អ្នកកាន់ករណី"ថ្មីដើម្បីកាន់ករណីបន្ត ឬត្រូវអនុវត្តជំហានទី២នៃការគ្រប់គ្រងករណី។ មន្ត្រីទទួលបន្ទុកមន្ទីរ ស.អ.យ មានភារកិច្ចសម្របសម្រួលក្នុងការផ្ទេរករណីនេះ និងបន្តត្រួតពិនិត្យករណី។

៥.៨ ក្នុងករណីជនរងគ្រោះផ្លាស់ប្តូរទីលំនៅទៅនៅខេត្តផ្សេង មន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ "អ្នកកាន់ករណី"ចាស់ ត្រូវស្នើសុំការសម្របសម្រួលពីមន្ត្រីទទួលបន្ទុក មន្ទីរ ស.អ.យ និងការអន្តរាគមន៍ពីមន្ត្រីទទួលបន្ទុកថ្នាក់ជាតិ ដើម្បីផ្ទេរករណីទៅកាន់មន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ "អ្នកកាន់ករណី"ថ្មីកាន់ករណីបន្ត ឬត្រូវអនុវត្តជំហានទី២ នៃការគ្រប់គ្រងករណី។ មន្ត្រីទទួលបន្ទុក មន្ទីរ ស.អ.យ "អ្នកត្រួតពិនិត្យករណី" ត្រូវបន្តត្រួតពិនិត្យករណី។

៥.៩ មន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ "អ្នកកាន់ករណី"ថ្មីត្រូវអនុវត្តជំហានទី២នៃការគ្រប់គ្រងករណីឡើងវិញ ចំពោះករណីជនរងគ្រោះដែលផ្លាស់ប្តូរទីលំនៅទៅនៅខេត្តផ្សេង ក្រោមការផ្តល់បច្ចេកទេសពីមន្ត្រីទទួលបន្ទុកមន្ទីរ ស.អ.យ និងសម្របសម្រួលពីមន្ត្រីទទួលបន្ទុកថ្នាក់ជាតិ។

ឧបសម្ព័ន្ធទី៣៖

-ទម្រងទី៥៖ទម្រង់តាមដាន

មន្ត្រីទទួលបន្ទុកមន្ទីរ ស.អ.យ ឬមន្ត្រីទទួលបន្ទុកថ្នាក់ជាតិ ត្រូវបញ្ចូលទិន្នន័យទម្រង់ទី៥៖ទម្រង់តាមដាន ដោយអនុវត្តតាមសៀវភៅណែនាំស្តីពីការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ( ឧបសម្ព័ន្ធទី៤ )។

***ការរៀបចំប្រជុំគ្រប់គ្រងករណី***

***កិច្ចប្រជុំគ្រប់គ្រងករណី*** *គឺជាកិច្ចប្រជុំផ្ទៃក្នុងស្ថាប័ន/ទីភ្នាក់ងារ ដែលត្រូវរៀបចំជាទៀងទាត់ និងមានការចូលរួមរបស់អ្នកគ្រប់គ្រង/អ្នកសម្របសម្រួល/ ប្រធាន(តាមភាពសមស្រប)និងអ្នកកាន់ករណី ដើម្បីពិនិត្យឡើងវិញលើបន្ទុកករណី។ កិច្ចប្រជុំទាំងនេះផ្តល់ឱកាសមួយ ដើម្បីពិនិត្យឡើងវិញលើករណីទាំងអស់ដែលបានបើក ដើម្បីប្រៀបធៀបកម្រិតនៃវឌ្ឍនភាពខុសៗគ្នារបស់ករណីជាក់លាក់ ពិភាក្សាប្រភេទនៃការឆ្លើយតបខុសៗគ្នា ចែករំលែកមេរៀនដែលទទួលបាន ចាត់អាទិភាពលើករណីជាក់លាក់សម្រាប់ការឆ្លើយតបបន្ទាន់ និងធ្វើសេចក្តីសម្រេចចិត្តរួមចំពោះករណីស្មុគស្មាញ។ នៅក្នុងកិច្ចប្រជុំទាំងនេះព័ត៌មានដែលត្រូវចែករំលែកគប្បីមានលក្ខណៈអនាមិក ដោយពិភាក្សាស្ថានភាពនានា ដោយមិននិយាយទៅដល់ព័ត៌មានអត្តសញ្ញាណរបស់ករណីឡើយ និងគប្បីរៀបចំនៅទីកន្លែងដែលមានការរក្សាការសម្ងាត់។ ជនរងគ្រោះ និងក្រុមគ្រួសារ ឬសាច់ញាតិមិនចូលរួមនៅក្នុងកិច្ចប្រជុំទាំងនេះឡើយ។ ក្នុងបរិបទបន្ទាន់ និងមានបញ្ហាស្មុគស្មាញ កិច្ចប្រជុំទាំងនេះគប្បីត្រូវរៀបចំប្រហែលម្តងក្នុងមួយសប្តាហ៍។*

**ជំហានទី៦៖ការបិទករណី**

ការបិទករណីគឺជាដំណាក់កាលចុងក្រោយនៃដំណើរការគ្រប់គ្រងករណី។ នៅក្នុងដំណាក់កាលនេះត្រូវមានការប្រជុំសម្របសម្រួលមុនពេលធ្វើការសម្រេចចិត្តបិទករណី។ ការបិទករណីមិនមានន័យថា ត្រូវលុបសំណុំឯកសារទាំងអស់ចោលឡើយ ដោយសារអាចមានការបើកសំណុំឯកសារនេះឡើងវិញ នៅពេលណាមួយដែលស្ថានភាពផ្លាស់ប្តូរ ឬជនរងគ្រោះទទួលរងបញ្ហាសារជាថ្មី។ សំណុំឯកសារនៃករណីដែលបានបិទ គប្បីត្រូវបានរក្សាទុកនៅកន្លែងដែលមានសុវត្ថិភាព ដោយអនុលោមទៅតាមពិធីសាររបស់ស្ថាប័ន/ទីភ្នាក់ងារ ឬច្បាប់ជាតិ។ ដើម្បីអនុវត្តការបិទករណី មន្ត្រីទទួលបន្ទុកមន្ទីរ ស.អ.យ មន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ និង អ្នកពាក់ព័ន្ធត្រូវអនុវត្តនីតិវិធីដូចខាងក្រោម៖

**<u>នីតិវិធីអនុវត្ត៖</u>**

៦.១ មន្ត្រីទទួលបន្ទុកថ្នាក់ជាតិត្រូវបិទករណីជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទជា "ជនបរទេស" បន្ទាប់ពីបានធ្វើមាតុភូមិនិវត្តទៅកាន់ប្រទេសកំណើតវិញ។ ការបិទករណីនេះមិនតម្រូវឱ្យបំពេញទម្រង់ទី៦៖ទម្រង់បិទករណី។

៦.២ មន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ "អ្នកកាន់ករណី" ត្រូវពិនិត្យមើលរបាយការណ៍នៃចុះតាមដាន និងពិនិត្យឡើងវិញរួមគ្នាលើកទី២ ដើម្បីពិចារណាសម្រេចថា តើត្រូវបិទករណី ឬបន្តករណី ?

៦.៣ មន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ "អ្នកកាន់ករណី" ស្នើសុំការឯកភាពពីមន្ត្រីទទួលបន្ទុកមន្ទីរ ស.អ.យ "អ្នកត្រួតពិនិត្យករណី" ដើម្បីរៀបចំកិច្ចប្រជុំសម្របសម្រួលមុននឹងសម្រេចថា "បិទករណី" ដោយត្រូវផ្អែកលើលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

**(ក).កត្តាបិទករណីជោគជ័យ**

- ជនរងគ្រោះរស់នៅក្នុងបរិយាកាសដែលនឹងនរ និងមានសុវត្ថិភាព (រយៈពេល១ឆ្នាំ)
- ជនរងគ្រោះមានជីវភាពសមរម្យ (រយៈពេល ១ឆ្នាំ)
- ជនរងគ្រោះមានសុខភាពរូបរាងកាយ
- ជនរងគ្រោះមានសុខុមាលភាពផ្លូវចិត្ត
- ជនរងគ្រោះមានឱកាសអភិវឌ្ឍន៍ខ្លួន
- ជនរងគ្រោះទទួលបានការគាំទ្រសង្គម-សេដ្ឋកិច្ច

**(ខ).កត្តាបិទករណីមិនជោគជ័យ**

- ជនរងគ្រោះទទួលមរណៈភាព
- ជនរងគ្រោះបានវត់បាត់ពីក្រុមគ្រួសារ ឬសាច់ញាតិ ឬមជ្ឈមណ្ឌល
- ជនរងគ្រោះបានផ្លាស់ប្តូរលំនៅ ហើយរកមិនឃើញ

៦.៤ ក្នុងករណីមិនទាន់សម្រេចគោលដៅដូចបានកំណត់នៅក្នុងផែនការករណី មន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ ត្រូវស្នើសុំទៅមន្ត្រីទទួលបន្ទុក មន្ទីរ ស.អ.យ អនុវត្តជំហានទី២ នៃការគ្រប់គ្រងករណីឡើងវិញ។ ផែនការករណីមានរយៈពេល ២៤(ម្ភៃបួន)ខែ ដោយគិតចាប់ផ្តើមអនុវត្តផែនការករណីឆ្នាំទី១។

៦.៥ មន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ "អ្នកកាន់ករណី" ស្នើសុំការឯកភាពពីមន្ត្រីទទួលបន្ទុក មន្ទីរ ស.អ.យ "អ្នកត្រួតពិនិត្យករណី" ដើម្បីសម្រេចបទករណី ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ(ក)និង(ខ)ខាងលើ។ អ្នកកាន់ករណីត្រូវបំពេញ**ទម្រង់ទី៦៖ទម្រង់បិទករណី** (ឧបសម្ព័ន្ធទី៣)។ ការសម្រេចបិទករណីផ្លូវការ "អ្នកត្រួតពិនិត្យករណី" ត្រូវស្នើសុំការសម្រេចពីប្រធានការិយាល័យសេវាសង្គមកិច្ច នៃមន្ទីរ ស.អ.យ រាជធានី ខេត្ត "អ្នកគ្រប់គ្រងករណី"។

៦.៦ មន្ត្រីទទួលបន្ទុក មន្ទីរ ស.អ.យ "អ្នកត្រួតពិនិត្យករណី"ត្រូវធ្វើរបាយការណ៍លទ្ធផលនៃការបិទករណីផ្លូវការ និងករណីដែលកំពុងបន្តអនុវត្តប្រចាំត្រីមាសជូន នាយកដ្ឋានគាំពារជនរងគ្រោះ នៃអគ្គនាយកដ្ឋានសេវាសង្គមកិច្ច ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

ឧបសម្ព័ន្ធទី៣៖

-ទម្រង់ទី៦៖ទម្រង់បិទករណី

មន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ មន្ត្រីទទួលបន្ទុកមន្ទីរ ស.អ.យ ឬមន្ត្រីទទួលបន្ទុកថ្នាក់ជាតិ ត្រូវបញ្ចូលទិន្នន័យទម្រង់ទី៦៖ទម្រង់ បិទករណី ដោយអនុវត្តតាមសៀវភៅណែនាំស្តីពីការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ(ឧបសម្ព័ន្ធទី៤)។

## ផ្នែកទី៦៖ យន្តការគាំទ្រ

### ៦.១.នាយកដ្ឋានគាំពារជនរងគ្រោះ

អនុវត្តមាត្រា ២១ អនុក្រឹត្យលេខ ៩៤ អនក្រ.បក ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលបានប្រគល់ភារកិច្ចឱ្យនាយកដ្ឋានគាំពារជនរងគ្រោះមានដូចខាងក្រោម៖

- គ្រប់គ្រង ដឹកនាំ និងចាត់ចែងការងារគាំពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងរំលោភផ្លូវភេទ ឬទម្រង់ផ្សេងទៀតនៃការរំលោភបំពានតាមបែបទាសភាពសម័យទំនើប
- អនុវត្តលិខិតបទដ្ឋានគតិយុត្ត សន្ធិសញ្ញា អនុសញ្ញាអន្តរជាតិ និងកិច្ចព្រមព្រៀងអន្តរជាតិនានាដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស រំលោភបំពានផ្លូវភេទ និងទម្រង់ផ្សេងៗទៀត
- អនុវត្តកម្មវិធីមាតុភូមិនិវត្តន៍ជនរងគ្រោះ ជនងាយរងគ្រោះ និងទម្រង់ផ្សេងៗទៀតដោយអំពើជួញដូរមនុស្ស និងរំលោភបំពានផ្លូវភេទ
- អនុវត្តការកំណត់អត្តសញ្ញាណ អន្តរាគមន៍វិបត្ត ការបញ្ជូន ការទទួល ការរៀបចំផែនការករណី ការប៉ាន់ប្រមាណ ការស្តារ ការធ្វើសមាហរណកម្ម ការតាមដាន ការបិទករណី និងការឧបត្ថម្ភគាំទ្រដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស រំលោភបំពានផ្លូវភេទ និងទម្រង់ផ្សេងៗទៀត
- គ្រប់គ្រងទិន្នន័យជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងរំលោភបំពានផ្លូវភេទគ្រប់ទម្រង់នៃការរំលោភបំពាន
- គាំពារជនរងគ្រោះ និងសាក្សីក្នុងរឿងក្តីក្នុងតុលាការ
- រៀបចំមណ្ឌលស្តារនីតិសម្បទាជនរងគ្រោះ និងសម្របសម្រួលមជ្ឈមណ្ឌលសំចតសម្រាប់ផ្តល់សេវាសង្គមកិច្ចដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស រំលោភផ្លូវភេទ និងទម្រង់ផ្សេងៗទៀតដែលបានធ្វើមាតុភូមិនិវត្តន៍

សម្របសម្រួលផ្តល់សេវាសាធារណៈមាន (ក)ការធ្វើមាតុភូមិនិវត្តន៍ ស្តារនីតិសម្បទា និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ច និងទម្រង់ផ្សេងៗទៀតនៃការរំលោភបំពាន(ខ)ការផ្តល់សេវាស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងសមាហរណកម្មជនរងគ្រោះនិងលិខិតបទដ្ឋានគតិយុត្តគាំទ្រការផ្តល់សេវា។

បណ្តុះបណ្តាលមន្ត្រីពាក់ព័ន្ធអនុវត្តសៀវភៅណែនាំស្តីពីនីតិវិធីប្រតិបត្តិកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ និងសម្របសម្រួលការអនុវត្តគ្រប់គ្រងករណីជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទប្រកបដោយការទទួលខុសត្រូវ។ នាយកដ្ឋានគាំពារជនរងគ្រោះត្រូវលើសំណើសុំថវិកាប្រចាំឆ្នាំសម្រាប់គាំទ្រសកម្មភាពដែលនាយកដ្ឋានទទួលខុសត្រូវនៅក្នុងសៀវភៅណែនាំនេះ។

### ៦.២.មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត

អនុវត្តប្រការ ៩ នៃប្រកាសលេខ ៣២១ ស.អ.យ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមន្ទីរ សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានីខេត្ត បានប្រគល់ភារកិច្ចផ្តល់សេវាគាំពារជនរងគ្រោះ និងគាំពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងរំលោភបំពានផ្លូវភេទ ផ្តល់បច្ចេកទេស

និងសម្របសម្រួលការគ្រប់គ្រងករណីអតិថិជនដែលត្រូវការសេវាសង្គមកិច្ច និងសហការពង្រឹងសមត្ថភាព ជំនាញវិជ្ជាជីវៈសង្គមកិច្ចដល់មន្ត្រី "អ្នកសង្គមកិច្ចអាជីពរង" រដ្ឋបាលក្រុង ស្រុក ខណ្ឌ និង"អ្នកសង្គមកិច្ចបឋម" ជាអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារ (អ.ក.ន.ក)រដ្ឋបាលឃុំ សង្កាត់។

សម្របសម្រួលផ្តល់សេវាសាធារណៈមាន(ក)ការផ្តល់សេវាស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងសមាហរណកម្មជនរងគ្រោះ(ខ)ការធ្វើមាតុភូមិនិវត្តន៍ ស្តារនីតិសម្បទា និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ច និងទម្រង់ផ្សេងៗទៀតនៃការរំលោភបំពាន និងលិខិតបទដ្ឋានគតិយុត្តគាំទ្រការផ្តល់សេវា។

សម្របសម្រួល និងតាមដានការអនុវត្តសម្របសម្រួលការអនុវត្តគ្រប់គ្រងករណីជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទប្រកបដោយការទទួលខុសត្រូវ និងលើកសំណើសុំថវិកាប្រចាំឆ្នាំសម្រាប់គាំទ្រសកម្មភាពដែលមន្ទីរ ស.អ.យ ទទួលខុសត្រូវនៅក្នុងសៀវភៅណែនាំនេះ។

## ៦.៣.ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ

ការិយាល័យសង្គមកិច្ចនិងសុខុមាលភាពសង្គមនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ អនុវត្តមុខងារ និងមុខងាររងមានចែងនៅក្នុងបទដ្ឋាន និងលិខិតបទដ្ឋានគតិយុត្តដូចខាងក្រោម៖

- អនុវត្តមុខងារដែលបានប្រគល់ដូចមានចែងនៅក្នុងឧបសម្ព័ន្ធទី១ និង៣(ដ)វិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៃអនុក្រឹត្យលេខ ១៨២ ១៨៣ និង១៨៤
- អនុវត្តប្រកាសលេខ ១៨៣ ស.អ.យ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្តីពីការអនុវត្តមុខងារនៃវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- អនុវត្តមាត្រា ៦ នៃអនុក្រឹត្យលេខ ៣៤ ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៧ ប្រគល់មុខងារ "ការត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល"
- អនុវត្ត អនុក្រឹត្យលេខ ១៥២ ស្តីពីការផ្ទេរធនធានថវិការដ្ឋជូនមូលនិធិក្រុង ស្រុក
- ចូលរួមអនុវត្តគោលនយោបាយ«ភូមិ-ឃុំ សង្កាត់មានសុវត្ថិភាព»ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២១
- អនុវត្តប្រកាសអន្តរក្រសួងលេខ ០៧៤ ប្រក ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០២៤ ស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្តីពីនីតិវិធីប្រតិបត្តិការកិច្ចការពារកុមារសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។
